មាតិកា

I.ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

២៤-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦២ ស្តីពី ការប្រោសព្រះរាជទាន នូវ គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ ចំពោះ លោក **យ៉ុំ សាខឹង** ៩៨៩៣

២៤-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៣ ស្តីពី ការដំឡើងឋានន្តរស័ក្តិថ្នាក់ ឧត្តមសេនីយ៍ទោ ជូនលោកឧត្តមសេនីយ៍ត្រី **ជឹម សារឿន** នាយនគរបាលជាតិ ជាន់ខ្ពស់នៃក្រសួងមហាផ្ទៃ ៩៨៩៤

២៤-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៤ ស្តីពី ការប្រោសព្រះរាជទានជាកិច្ចបច្ឆាមរណៈ នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះសពនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន ០៨ រូប ៩៨៩៥

២៤-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៥ ស្តីពី ការប្រោសព្រះរាជទាននូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ នាយទាហាន មន្ត្រីរាជការ និង សប្បុរសជន ចំនួន ២១ រូប ៩៨៩៦

២៧-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៦៧ ស្តីពី ការតែងតាំង ឯកឧត្តម **តែ ណាវុធ** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ រដ្ឋលេខាធិការ ជំនួសឯកឧត្តម **ពេជ ឌុន** ដែលត្រូវបានចាត់ឱ្យទទួលភារកិច្ចថ្មី ៩៨៩៨

II.រាជរដ្ឋាភិបាល

១.អនុក្រឹត្យ

២៨-១២-២០១០ -អនុក្រឹត្យលេខ ១៧១ អនក្រ.បក ស្តីពី ការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស "បូកគោ" និង ឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ "គីរីរម្យ" ៩៨៩៩

២៩-១២-២០១០ -អនុក្រឹត្យលេខ ១៧២ អនក្រ.បក ស្តីពី ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន ៩៩០២

៣០-១២-២០១០ -អនុក្រឹត្យលេខ ១៧៣ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៩៧២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និង ស្រុកស្នួល ខេត្តក្រចេះ ៩៩០៨

៣០-១២-២០១០ -អនុក្រឹត្យលេខ ១៧៤ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៩៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និង ស្រុកស្នួល ខេត្តក្រចេះ ៩៩១១

៣០.១២.២០១០ - អនុក្រឹត្យលេខ ១៧៥ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៥.០៨៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង ខេត្តក្រចេះ ៩៩១៤
៣០.១២.២០១០ - អនុក្រឹត្យលេខ ១៧៦ អនក្រ.បក ស្តីពី ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៩៩១៧
៣០.១២.២០១០ - អនុក្រឹត្យលេខ ១៧៧ អនក្រ.បក ស្តីពី ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារ ធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ៩៩១៩
៣០.១២.២០១០ - អនុក្រឹត្យលេខ ១៧៨ អនក្រ.បក ស្តីពី ការកែសម្រួលមាត្រា ២ ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួល មាត្រា ២ ថ្មី នៃអនុក្រឹត្យ លេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែមេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ៩៩២១
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៤ អនក្រ.តត ស្តីពី ការប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៩៩២៤
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៥ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៩៩២៥
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៩២៦
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៧ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៩៩២៧
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៨ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៩២៨
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៤៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៩៣០
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥០ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៩៣៦
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៣៨
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៣៩
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤០
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤១
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៥ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤២
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៣
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៤
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៨ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៥
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៥៩ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៦
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៦០ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៧
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៦១ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៨
២៨.១២.២០១០ - អនុក្រឹត្យលេខ ១២៦២ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៤៩

២៨-១២-២០១០ -អនុក្រឹត្យលេខ ១២៦៣ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៥០

២៨-១២-២០១០ -អនុក្រឹត្យលេខ ១២៦៤ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៩៩៥១

២-សេចក្តីសម្រេច

២៨-១២-២០១០ -សេចក្តីសម្រេចលេខ ៧៤ សសរ ស្តីពី ការបង្កើតគណៈបញ្ជាការ ការពារសន្តិសុខ គោលដៅ ទីស្តីការគណៈរដ្ឋមន្ត្រី និង ទីស្តីការនាយករដ្ឋមន្ត្រី ៩៩៥២

III-ការងារបណ្តាក្រសួង

១-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-១២-២០១០ -ប្រកាសលេខ ១១៩៨ សហវ.ប្រក ស្តីពី ការកែសម្រួលអត្រាពន្ធគយលើមុខទំនិញនាំចូលមួយចំនួន ៩៩៥៥

២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ & ក្រសួងយុត្តិធម៌

២៨-១២-២០១០ -ប្រកាសអន្តរក្រសួងលេខ ១១៩២ សហវ.កយ.ប្រក ស្តីពី ការកំណត់កម្រៃសេវារដ្ឋបាល នៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ៩៩៥៧

៣-ធនាគារជាតិ នៃ កម្ពុជា

២១-១២-២០១០ -ប្រកាសលេខ ធ ១២-០១០-២០៦ ប្រក ស្តីពី ការប្រឆាំងការសម្អាតប្រាក់ និង ហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិ នៃ កម្ពុជា ៩៩៦០

៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ & ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១៣-១២-២០១០-ប្រកាសអន្តរក្រសួងលេខ ១៤០/៦០៦ ប្រក.កយ.កសក/១០ ស្តីពី ការផ្តល់នីតិសម្បទា ជាមន្ត្រីនគរបាលយុត្តិធម៌ ៩៩៩៦

៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

២០-១២-២០១០ -ប្រកាសលេខ ១០១០ ឧរថ.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ហ្វៀវដុង (ខេមបូឌា) លីមីធីត បង្កើតរោងចក្រ ផលិតសម្លៀកបំពាក់, ស្រោមដៃ, កន្សែងបង់ក, មួក ១០០០៧

២០-១២-២០១០ -ប្រកាសលេខ ១០១១ ឧរថ.កឧ.ប្រក ស្តីពីការអនុញ្ញាតឱ្យក្រុមហ៊ុន ៧ អេហ្វ ធីឌី ខូអិលធីឌី បង្កើតរោងចក្រ ផលិតសសរគ្រឹះពីបេតុង, បង្គោលភ្លើងពីបេតុង ១០០១១

៦-ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៥-៣-២០១០ -លិខិតបញ្ជាក់លេខ ១១៣៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ម៉ូឲ យូន គ្រុប ១០០១៥

បញ្ជាក់៖ ព្រះរាជក្រម, ព្រះរាជក្រឹត្យ, អនុក្រឹត្យ... ដែលត្រូវចេញផ្សាយចុងឆ្នាំ ២០១០ នឹងបន្តចុះផ្សាយក្នុងរាជកិច្ច ដើមឆ្នាំ ២០១១ ។

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ

ចំពោះ

លោក យ៉ាំ សាខឹង

ដែលបានរួមចំណែកក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ
លើការអភិវឌ្ឍន៍មូលដ្ឋានក្នុងខេត្តកណ្តាល ទទួលបានជោគជ័យគួរជាទីមោទនៈ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ល. ១០១២.៩៧៩

នរោត្តម សីហមុនី

លេខ: ៨៧០ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ូ ម៉ឹនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដំឡើងឋានន្តរស័ក្តិថ្នាក់ **ឧត្តមសេនីយ៍ទោ** ជូនលោកឧត្តមសេនីយ៍ត្រី **ខឹម សារឿន** អត្តលេខ ០១៨៩ នាយនគរបាលជាតិជាន់ខ្ពស់ នៃក្រសួងមហាផ្ទៃ ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឲ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ.ល. ១០១២.៩៤០

លេខៈ ៨៥៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ២០១០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី / អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ជាកិត្តិយសបច្ឆាមរណៈ

ចំពោះ

សពនាយទាហាន នៃកងយោធពលខេមរភូមិន្ទ ចំនួន០៨រូប មានគុណបំណាច់និងស្នាដៃល្អ
ក្នុងការធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីការពារជាតិមាតុភូមិ និងប្រជារាស្ត្រ កន្លងមក

នូវ

ក-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-	ឧត្តមសេនីយ៍ឯក	ប្រូចថ ប៊ុនធុល	អត្តលេខ ០០០១៧៨
២-	ឧត្តមសេនីយ៍ឯក	អន កំសត់	អត្តលេខ ០០០៦៣៦
៣-	ឧត្តមសេនីយ៍ទោ	កៀក សារី	អត្តលេខ ០០០៧៥៥
៤-	ឧត្តមសេនីយ៍ត្រី	នុត ផូ	អត្តលេខ ០០២០៩៨
៥-	ឧត្តមសេនីយ៍ត្រី	គៀត ប៊ុនហុង	អត្តលេខ ០០០៣៩២

ខ-គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-	ឧត្តមសេនីយ៍ត្រី	ឡាំ ច័ន្ទវណ្ណដា	អត្តលេខ ០០២២៣១
២-	វរសេនីយ៍ឯក	សួស ចំរើន	អត្តលេខ ០០៤២១៨
៣-	វរសេនីយ៍ឯក	ឌឹម បូរ៉ា	អត្តលេខ ០២២៣០១

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០១២. ៩៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៥៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

យុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

ចំពោះ

ឯកឧត្តម លោកជំទាវ នាយនគរបាលជាតិ នាយទាហាន មន្ត្រីរាជការ និងសប្បុរសជន ដែលបានបរិច្ចាគធនធាន ចូលរួមកសាងហេដ្ឋារចនា សម្ព័ន្ធ សង្គមជាតិ និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ នៅស្រុកល្វាឯម ខេត្តកណ្តាល

នូវ

ក. គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់មហាសេនា :

១-លោកជំទាវ **ជួន គីម**

២-លោកឧត្តមសេនីយ៍ទោ **ស្រាក់ ភាណសារ៉ា** អត្តលេខ០១៦៥

៣-លោកឧត្តមសេនីយ៍ត្រី **ម៉ុន ថាវឌ្ឍន** អត្តលេខ០១០១៦

ខ. គ្រឿងឥស្សរិយយស សេនាជ័យសិទ្ធិ :

១-លោកឧត្តមសេនីយ៍ត្រី **ម៉ាត់ ណារី** អត្តលេខ០១៥៣

២-លោកឧត្តមសេនីយ៍ត្រី **សួន គីមស្រ៊ន** អត្តលេខ០១៣៣

៣-លោកឧត្តមសេនីយ៍ត្រី **យន់ ខេង** អត្តលេខ០១០៨៩

៤-លោកវរសេនីយ៍ឯក **ផាខ ពៅ** អត្តលេខ១២៦៤៤

គ. គ្រឿងឥស្សរិយយស សុវត្ថារា ថ្នាក់មហាសេរីវឌ្ឍន៍ :

១-ឯកឧត្តម **ឯម សំអាន**

២-លោកឧត្តមសេនីយ៍ឯក **អៅ គីមឈួន** អត្តលេខ០០៣៤

៣-លោកឧត្តមសេនីយ៍ត្រី **ឯម ចិចិត្រ** អត្តលេខ០៤៤៤៥

៤-លោកឧត្តមសេនីយ៍ត្រី **ជុំ ហេង** អត្តលេខ០៦២២១

៥-លោកស្រី **ឯម សុជាតិ**

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឃ. គ្រឿងឥស្សរិយយស មុនីសារាភណ្ឌ ថ្នាក់មហាសេរីវឌ្ឍន៍ :

១-លោកវរសេនីយ៍ទោ **សំ ជាវ៉ា** អត្តលេខ០៨dddd

២-លោកវរសេនីយ៍ឯក **លី គុងឃ្លារ** អត្តលេខ១៦២០៩០

៣-លោកវរសេនីយ៍ឯក **សៀង សេង** អត្តលេខ០១៨១៣

៤-លោក **សេរ គិរុណ**

៥-លោក **ឃុង លី**

ង. គ្រឿងឥស្សរិយយស មុនីសារាភណ្ឌ ថ្នាក់មហាសេនា :

១-ឯកឧត្តម **ធីង ចាន់ថូ**

២-លោកឧត្តមសេនីយ៍ត្រី **ចាំ សាច័ន** អត្តលេខ០១៧៦

៣-លោក **គង សោផាន**

៤-លោកស្រី **អ៊ុន សុភារី**

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ល.១០១២.៩៩២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០ លេខ: ៨៥៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាពការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២០៩/១១៨១ ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងការកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តម **តែ ណាវុធ** ជាអគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ជំនួសឯកឧត្តម **ពេជ ឌុន** ដែលត្រូវបានចាត់ឲ្យទទួលភារកិច្ចថ្មី។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣.រ.ល. ១០១២. ៩៨៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៥៦ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនគេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤១ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»

និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នសរកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី តំបន់ការពារធម្មជាតិ

-បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពី ការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

-បានឃើញអនុក្រឹត្យលេខ ៥៧អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

មាត្រា១.-

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» ទំហំ១៥៩.៩៥៨(មួយរយហាសិបបួនពាន់ បួនរយហាសិបប្រាំបី)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

Nº	X	Y	Nº	X	Y	Nº	X	Y
A	402810	1168653	J	383146	1220836	S	406537	1231627
B	400650	1168148	K	390001	1228888	T	408004	1225468
C	395184	1171052	L	390000	1231510	U	408004	1215883
D	387286	1171587	M	392423	1231605	V	403996	1210001
E	384045	1174392	N	394181	1227998	W	404999	1197997
F	378487	1187086	O	396796	1232460	X	408869	1180152
G	377158	1195536	P	395566	1236924	Y	404933	1173146
H	379176	1205847	Q	402616	1238796	Z	405501	1170055
I	384777	1209233	R	404316	1232325			

មាត្រា២.-

ត្រូវបានកែសម្រួល និងកំណត់ផ្ទៃដីឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គីរីរម្យ»ទំហំ៣៥.២៣២(សាមសិបប្រាំពាន់ ពីររយសាមសិបពីរ)ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ២ កំណត់ដោយបណ្តាចំណុចគោលដែលមាននិយាមកាដូចខាងក្រោម៖

Nº	X	Y	Nº	X	Y
A	402619	1238913	G	396523	1261014
B	395542	1237006	H	402131	1260618
C	393585	1238477	I	405891	1257039
D	388012	1245801	J	405620	1249874
E	390237	1260167	K	404103	1244483
F	392695	1261817			

មាត្រា៣.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ខេត្តកំពត និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧២ . អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១. នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ហើយមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ០១.នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងមានការកែប្រែក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៥/០១ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការកែតម្រូវនៃច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២១ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីការកែសម្រួល អត្រាពន្ធគយ និងអាករលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ១២០ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញ និងសេវាមួយចំនួន និងអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការកែប្រែអត្រាពន្ធគយ និងអាករពិសេសលើទំនិញមួយចំនួន

- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១០ ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

មាត្រា ១.-

ត្រូវបានកែសម្រួលអត្រាអាករពិសេសលើមុខទំនិញនាំចូលចំនួន ១៩ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករពិសេសពី ១០% ទៅ ២០% ចំនួន ១៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ៨៧០២.១០.១១ ៨៧០២.១០.១២ ៨៧០២.១០.១៣ ៨៧០២.១០.១៩ ៨៧០២.១០.២១ ៨៧០២.១០.២២ ៨៧០២.១០.២៣ ៨៧០២.១០.២៩ ៨៧០២.៩០.១១ ៨៧០២.៩០.១៩ ៨៧០២.៩០.៩១ ៨៧០២.៩០.៩៩ និង ៨៧១៦.៩០.៩៩ ។
- បន្ថយអត្រាអាករពិសេសពី ៣៣,៣៣% មក ១០% ចំនួន ០៦ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៧១០.១១.១១ ២៧១០.១១.១២ ២៧១០.១១.១៣ ២៧១០.១១.១៤ ២៧១០.១១.១៥ និង ២៧១០.១១.១៦ ។

មាត្រា ២.-

ត្រូវបានកែសម្រួលអត្រាអាករនាំចេញលើមុខទំនិញចំនួន ២៧ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- តម្លើងអត្រាអាករនាំចេញពី ១០% ទៅ ២០% លើមុខទំនិញចំនួន ២០ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥១៥.១១.០០ ២៥១៥.២០.០០ ២៥១៦.១១.០០២៥១៦.២០.០០ ២៥១៦.៩០.០០ ២៥១៧.១០.០០ ២៥១៧.២០.០០ ២៥១៧.៤១.០០ ២៥១៧.៤៩.០០ ៧២០៤.១០.០០ ៧២០៤.២១.០០ ៧២០៤.២៩.០០ ៧២០៤.៣០.០០ ៧២០៤.៤១.០០ ៧២០៤.៥០.០០ ៧៤០៤.០០.០០ ៧៦០២.០០.០០ ៧៨០២.០០.០០ ៧៩០២.០០.០០ និង ៨០០២.០០.០០ ។
- បន្ថយអត្រាអាករនាំចេញពី ១០% មក ០% លើមុខទំនិញចំនួន ០៧ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញនៃទីតាំងរងលេខ ២៥២៣.១០.១០ ២៥២៣.១០.៩០ ២៥២៣.២១.០០ ២៥២៣.២៩.១០ ២៥២៣.២៩.៩០ ២៥២៣.៣០.០០ និង ២៥២៣.៩០.០០ ។

មាត្រា ៣.-

ត្រូវបានកំណត់ការប្រមូលអាករនាំចេញតាមរបៀប "ពន្ធគិតតាមឯកតា" លើមុខទំនិញជ័រកៅស៊ូចំនួន ៥៦ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ តាមរូបភាពដូចខាងក្រោម ៖

- ជាប់អាករនាំចេញ ៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញទាបជាង ២០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ១៥០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ២០០០ តែទាបជាង ៣០០០ ដុល្លារអាមេរិកក្នុង ១ តោន ។
- ជាប់អាករនាំចេញ ២០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៣០០០ តែទាបជាង ៤០០០ ដុល្លារអាមេរិកក្នុង ១ តោន ។

- ជាប់អាករនាំចេញ ៣០០ ដុល្លារអាមេរិកក្នុង ១ តោន បើតម្លៃគិតអាករនាំចេញចាប់ពី ៤០០០ ដុល្លារអាមេរិកឡើងក្នុង ១ តោន ។

មាត្រា ៤.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកចាត់ចែងអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

__ចម្លងជូន៖__

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- គ្រប់សាលាខេត្ត និងសាលារាជធានី
- ដូចមាត្រា ៥
- រាជកិច្ច

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ១៧៥អនក្រ.បក ចុះថ្ងៃទី២៦ខែ ធ្នូ ឆ្នាំ ២០១០
ស្តីពីការកែសម្រួលអត្រាអាករពិសេស និងអត្រាអាករនាំចេញលើទំនិញមួយចំនួន

Head.	Tariff Code	បរិយាយមុខទំនិញ	Description of Goods
40.01		កៅស៊ូធម្មជាតិ ជ័របាលាតា ជ័រ guttapercha ជ័រ guayule ជ័រល្មុត និងជ័រធម្មជាតិ ស្រដៀងគ្នាក្នុងទំរង់ដើម ឬជាផ្ទាំង ជាសន្លឹក ឬជាបន្ទះ ។	**Natural rubber, balata, gutta-percha, guayule, chicle and similar natural gums, in primary forms or in plates, sheets or strip.**
	4001.10.11	- - - កំហាប់សង់ទ្រីហ្វុយ	- - - Centrifuge concentrate
	4001.10.19	- - - ផ្សេងទៀត	- - - Other
	4001.10.21	- - - កំហាប់សង់ទ្រីហ្វុយ	- - - Centrifuge concentrate
	4001.10.29	- - - ផ្សេងទៀត	- - - Other
	4001.21.10	- - - គុណភាព Rss1	- - - RSS Grade 1
	4001.21.20	- - - គុណភាព Rss2	- - - RSS Grade 2
	4001.21.30	- - - គុណភាព Rss3	- - - RSS Grade 3
	4001.21.40	- - - គុណភាព Rss4	- - - RSS Grade 4
	4001.21.50	- - - គុណភាព Rss5	- - - RSS Grade 5
	4001.21.90	- - - ផ្សេងទៀត	- - - Other
	4001.22.10	- - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី	- - - Standard Indonosian rubber SIR 3 CV
	4001.22.20	- - - កៅស៊ូស្តង់ដាឥណ្ឌូណេស៊ី ផ្សេងទៀត	- - - Other Standard Indonesian rubber
	4001.22.30	- - - កៅស៊ូស្តង់ដា ម៉ាឡេស៊ី	- - - Standard Malaysian rubber
	4001.22.40	- - - កៅស៊ូស្តង់ដា សិង្ហបុរី	- - - Specified Singapore rubber
	4001.22.50	- - - កៅស៊ូស្តង់ដា ថៃ	- - - Thai tested rubber
	4001.22.90	- - - ផ្សេងទៀត	- - - Other
	4001.29.10	- - - សន្លឹកចំអិនដោយខ្យល់	- - - Air-dried sheet
	4001.29.20	- - - ជ័រក្រេបរាវ (តាលិច)	- - - Latex crepe
	4001.29.30	- - - ជ័រក្រេបបាត	- - - Sole crepe
	4001.29.40	- - - ជ័រក្រេបច្នៃឡើងវិញរាប់បញ្ចូលទាំងជ័រក្រេប	- - - Remilled crepe, including flat bark crepe
	4001.29.50	- - - ជ័រក្រេបផ្សេងទៀត	- - - Other crepe
	4001.29.60	- - - កៅស៊ូកែច្នៃគុណភាព	- - - Superior processing rubber
	4001.29.70	- - - កំណកពពុះកៅស៊ូខាងលើ	- - - Skim rubber
	4001.29.80	- - - កំទេចសំណល់កៅស៊ូ(ដើមឈើ ដី ឬ ផ្សែង) និងខាប់ឡា (cup lump)	- - - Scrap (tree, ea[illegible]nd cup lump
	4001.29.90	- - - ផ្សេងទៀត	- - - Other
	4001.30.11	- - - ក្នុងទម្រង់ដើម	- - - In primary form

	4001.30.19	- - - ផ្សេងទៀត	- - - Other
	4001.30.91	- - - ក្នុងទម្រង់ដើម	- - - In primary form
	4001.30.99	- - - ផ្សេងទៀត	- - - Other
40.02		កៅស៊ូសំយោគ និងកៅស៊ូចេញមកពីប្រេងផ្សេងៗក្នុងទំរង់ដើម ឬផ្ទាំង ជាសន្លឹក ឬជាល្បាយផលិតផលនៃទីតាំងលេខ ៤០.០១ ជាមួយផលិតផលនៃទីតាំងនេះ ក្នុងទម្រង់ដើម ឬជាផ្ទាំង ជាស្លឹក ឬជាបង់ធំ ។	**Synthetic rubber and factice derived from oils, in primary forms or in plates, sheets or strip; mixtures of any product of heading No. 40.01 with any product of this heading, in primary forms or in plates, sheets or strip.**
	4002.11.00	- - ជ័រកៅស៊ូរាវ	- - Latex
	4002.19.00	- - ផ្សេងទៀត	- - Other
	4002.20.00	- កៅស៊ូ ប៊ុយតាឌីយ៉ែន (BR)	- Butadiene rubber (BR)
	4002.31.00	- - កៅស៊ូអ៊ីសូប៊ុយតែន- អ៊ីសូប្រ៉ែន (ប៊ុយទីល) (IIR)	- - Isobutene-isoprene (butyl) rubber (IIR)
	4002.39.00	- - ផ្សេងទៀត	- - Other
	4002.41.00	- - ជ័រកៅស៊ូរាវ	- - Latex
	4002.49.00	- - ផ្សេងទៀត	- - Other
	4002.51.00	- - ជ័រកៅស៊ូរាវ	- - Latex
	4002.59.00	- - ផ្សេងទៀត	- - Other
	4002.60.10	- - ក្នុងទម្រង់បឋម	- - In primary forms
	4002.60.90	- - ផ្សេងទៀត	- - Other
	4002.70.00	- កៅស៊ូអេទីឡែន - ប្រូពីឡែន- មិនលាយជាមួយឌីយ៉ែន (EPDM)	- Ethylene-propylene-non-conjugated diene rubber (EPDM)
	4002.80.10	- - ល្បាយកៅស៊ូធម្មជាតិជាមួយកៅស៊ូសាំងតេទិករាវ	- - Mixture of natural rubber latex with synthetic rubber latex
	4002.80.90	- - ផ្សេងទៀត	- - Other
	4002.91.10	- - - ជ័រកៅស៊ូរាវ	- - - Latex
	4002.91.90	- - - ផ្សេងទៀត	- - - Other
	4002.99.10	- - - កៅស៊ូធម្មជាតិផ្សាំ នៃប៉ូលី(មេទីល- មេតាគ្រីលាត)	- - - Of poly(methyl-methacrylate)graft natural rubber
	4002.99.90	- - - ផ្សេងទៀត	- - - Other
40.03	4003.00.00	កៅស៊ូច្នៃឡើងវិញក្នុងទំរង់ដើម ឬជាផ្ទាំង ជាសន្លឹក ឬជាបង់ធំ	**Reclaimed rubber in primary forms or in plates, sheets or strip.**
40.04	4004.00.00	សំណល់ កំទេចកៅស៊ូ (ក្រៅពីកៅស៊ូរឹង) ម្សៅ និងគ្រាប់បានមកនោះ	**Waste, parings and scrap of rubber (other than hard rubber) and powders and granules obtained therefrom.**
40.05		កៅស៊ូល្បាយមិនទាន់លាយស្ពាន់ធ័រ ក្នុងទំរង់ដើមជាផ្ទាំង ជាសន្លឹក ឬជាបង់ធំ	**Compounded rubber, unvulcanised, in primary forms or in plates, sheets or strip.**
	4005.10.00	- លាយជាមួយកាបោនខ្មៅ ឬស៊ីលីស	- Compounded with carbon black or silica
	4005.20.00	- ល្បាយ ល្បាយមិនរលាយក្រៅពីល្បាយនៃទីតាំងរងលេខ ៤០.០៥.១០	- Solutions, dispersions other than those of subheading No. 4005.10

	4005.91.00	- - ផ្ទាក សន្លឹក បង់ជ័	- - Plates, sheets and strip
	4005.99.00	- - ផ្សេងទៀត	- - Other
40.06		ទំរង់ផ្សេងទៀត (ឧទាហរណ៍ដើមមូលវែង ទិប និងប្រូហ្វីឡេ) និងវត្ថុ (ឧទា. ចាសកង់) ធ្វើពីកៅស៊ូមិនទាន់លាយស្ពាន់ធ័រ ។	**Other forms (for example, rods, tubes and profile shapes) and articles (for example, discs and rings), of unvulcanised rubber.**
	4006.10.00	- ប្រូហ្វីឡេសំរាប់ចាក់កង់រថយន្តឡើងវិញ	- "Camel-back" strips for retreading rubber tyres
	4006.90.00	- ផ្សេងទៀត	- Other
40.07	4007.00.00	សសៃ និងខ្សែធ្វើពីកៅស៊ូលាយស្ពាន់ធ័រ	**Vulcanised rubber thread and cord.**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១២៣ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៩៧២ ហិកតា

ស្ថិតនៅក្នុងតំបន់ទួមិសាស្រ្ត ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១: –

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៩៧២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំដីវីផុង ឃុំកំពង់ដំរី ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ២២៩៤ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២: –

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣: –

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤ –

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ

ផែនទី៖ ចំណុចគោលក្តារដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ជុងទៀង (ខេមបូឌា) រ៉ាប់ប៊ើរ ឌីវេឡុបមេន ខមភេនី លីមីតធីត(ជាខេមរភូមិ)
ស្ថិតនៅភូមិ ឃុំជីផុង ឃុំកំពង់ដំរី ស្រុកស្នួល និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ



បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ឆ្នាំ ២០១០

មេឃុំ

សួម.សារិត

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ស្នួល ថ្ងៃទី ឆ្នាំ ២០១០

អភិបាលស្រុក

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី ឆ្នាំ ២០១០

គួយ. ហួត

បានឃើញ និង ឯកភាព

សូមគោរពជូន ឯកឧត្តមអភិបាលខេត្តមេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី ឆ្នាំ ២០១០

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត

សុង_សុខានី

បានឃើញ និង ឯកភាព

គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម

រុក្ខាប្រមាញ់ និង នេសាទ មេត្តាពិនិត្យ និង សម្រេច

ក្រចេះ ថ្ងៃទី ឆ្នាំ ២០១០

អភិបាលខេត្ត

ទី_ទៀង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៤ .អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៩៩២ ហិកតា

ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកឆ្លូង និងស្រុកស្នួល ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៦.៩៩២ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំព្រែកសាម៉ាន់ ឃុំជីរ៉ផុង ស្រុកឆ្លូង និងឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ២២៩២ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ៨ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល :</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ


Coordinate System
Horizontal Datum : Indian 1960
Zone : 48
Projection : UTM
Spheroid : Everest
Scale 1:60,000

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០៨៨ ហិកតា ស្ថិតនៅឃុំទូកមាស ស្រុកឆ្លូង ខេត្តក្រចេះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងប្បញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

ស ម្រេ ច

មាត្រា១:-

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៥.០៨៨ ហិកតា ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំដំរីផុង និងឃុំកំពង់ដំរី ស្រុកស្នួល ខេត្តក្រចេះ ដើម្បីធ្វើការវិនិយោគដាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកាលេខ២២៩៣ ចណ.ក្រច ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ របស់សាលាខេត្តក្រចេះ ជាឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

មាត្រា២:-

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១នៃអនុក្រឹត្យនេះ ត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍ របស់រាជរដ្ឋាភិបាល ។

មាត្រា៣:-

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៤-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង ស្ថាប័ន និងអភិបាលខេត្តក្រចេះ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ផែនទី: ចំណុចគោលក្បាលដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ចំនួសុភា អគ្គិទេយ្យន៍ ស្ថិតនៅក្នុង ឃុំជីផុច និង ឃុំកំពង់ដី ស្រុកឆ្លូង ខេត្តក្រចេះ



សញ្ញាសំគាល់

- ចំណុចគោលក្បាលដី
- ចំណុចក្បាលដីសុំបង្កើតសហគមន៍ព្រៃឈើ
- ភូមិ
- ព្រំប្រទល់ឃុំ
- ព្រំប្រទល់ស្រុក
- ព្រំប្រទល់ខេត្ត
- ផ្លូវទឹក
- ខ្សែបណ្ដាក់កំពស់
- ផ្លូវជាតិ និង ផ្លូវលើកថ្មី
- ផ្លូវរទេះ
- ផ្លូវលើង

គម្របព្រៃឈើ ២០០៦- ២០១០ ហ.ត

- ព្រៃស្រោង- ៧៩៣៧ ហ.ត
- ព្រៃពាក់កណ្ដាលស្រោង- ៩០៧ ហ.ត
- ព្រៃល្បោះ- ៦ ហ.ត
- ព្រៃឫស្សីលាយព្រៃ-១០ ហ.ត
- ដីគ្មានគម្របព្រៃ-១៩០ ហ.ត
- ព្រំប្រទល់ដីស្នើសុំ -៩០១០ ហ.ត
- តំបន់ការពារផ្លូវទឹកម្ខាង១០០ម -៥៦៩.១០ ហ.ត
- ដីបម្រុងសម្បទានសង្គមកិច្ច -៦០០ហ.ត
- ដីសុំបង្កើត ស.ក.ព.ឈ -២៧៧៩.៤ហ.ត
- ផ្ទៃដីជាក់ស្ដែងប្រជាពលរដ្ឋដែលនៅរាយប៉ាយ- ២៧៩.៥ ហ.ត

ផ្ទៃដីនៅសល់សរុប - ៥០៨៨ ហ.ត

Scale 1:60,000
0 600 1,200 M

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តពិនិត្យ និង សម្រេច
ឆ្លូង ថ្ងៃទី...ខែ...ឆ្នាំ ២០១០
មេឃុំជីផុច
សូម.សារិត

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តពិនិត្យ និង សម្រេច
ក្រចេះ ថ្ងៃទី...ខែ...ឆ្នាំ ២០១០
ប្រធានមន្ទីរកសិកម្មខេត្ត
គុយ. ហួត

លេខ:...
បានឃើញ និង ឯកភាព
សូមគោរពជូន ឯកឧត្តមអភិបាលខេត្តពិនិត្យ និង សម្រេច
ក្រចេះ ថ្ងៃទី...ខែ...ឆ្នាំ ២០១០
ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត
ម៉ាង. សុជាត

លេខ:...
បានឃើញ និង ឯកភាព
គោរពជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម
រុក្ខាប្រមាញ់ និង នេសាទ មេត្តាពិនិត្យ និង សម្រេច
ក្រចេះ ថ្ងៃទី...ខែ...ឆ្នាំ ២០១០
អភិបាលខេត្ត
ខរិ.តៀង

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៦ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ ប្រើប្រាស់ដោយចីរភាព
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

សម្រេច

មាត្រា១៖

ត្រូវបានកំណត់តំបន់គ្រប់គ្រងក្នុងដែនជម្រកសត្វព្រៃភ្នំសំកុស លើផ្ទៃដីទំហំ១.៩៥០ហិកតា (**មួយពាន់ ប្រាំបួនរយ ហាសិបហិកតា**) ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព ស្ថិតនៅក្នុងភូមិសាស្ត្រ **ស្រុកវាលវែង ខេត្តពោធិសាត់** សម្រាប់ផ្តល់ជូនក្រុមហ៊ុន **អិម ឌី អេស អាហ៉ារណេ នីហ៉ារណេ** ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍លើវិស័យកសិ-ឧស្សាហកម្ម (ដំណាំកៅស៊ូ) ដែលមានទីតាំង និងនិយាមកាដូចមានក្នុងផែនទីភ្ជាប់នឹងលិខិតលេខ ១៤៩០ សជណ.កស ចុះថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១០ជាឧបសម្ព័ន្ធ។

មាត្រា២៖

ត្រូវបាននិរាករណ៍អនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព។

មាត្រា៣៖

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា៤៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តពោធិសាត់ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ ប្រើប្រាស់ដោយចីរភាព
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល ។

សម្រេច

មាត្រា១ៈ

ត្រូវធ្វើវិសោធនកម្មអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ក្នុងមាត្រា៣ នៅបន្ទាត់ទី៣ ត្រូវបានកែសម្រួលពី «.....**គណៈអភិបាលខេត្តក្រចេះ** » មកជាៈ «.... **គណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ**» វិញ ដែលមានខ្លឹមសារ នៃមាត្រា៣ ដូចខាងក្រោមៈ

«រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ **និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ»។

មាត្រា២៖

ខ្លឹមសារនៃមាត្រាដទៃផ្សេងទៀត របស់អនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិ ទៅជាតំបន់ប្រើប្រាស់ដោយចីរភាព នៅតែមានសុពលភាពជាគតិយុត្តិដដែល។

មាត្រា៣៖

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ ធ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

<u>កន្លែងទទួល៖</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ, កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការកែសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល
- តាមសំណើរបស់ប្រធានគណៈកម្មាធិការជាតិបណ្តុះបណ្តាល

សម្រេច

មាត្រា មួយ.-

ត្រូវបានកែសម្រួលមាត្រា ២ថ្មី នៃអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៨ ស្តីពីការសម្រួលមាត្រា ២ នៃអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការបង្កើតគណៈកម្មាធិការជាតិបណ្តុះបណ្តាល ដូចតទៅ ÷

មាត្រា ២ថ្មី(ពីរ)..

សមាសភាពនៃគណៈកម្មាធិការជាតិបណ្តុះបណ្តាល មានដូចខាងក្រោម ÷

១- ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	ប្រធាន
២- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	អនុប្រធាន
៣- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	អនុប្រធាន
៤- តំណាងក្រសួងអប់រំ យុវជន និងកីឡា	អនុប្រធាន
៥- ប្រធានសភាមុខរបរ និងមីក្រូសហគ្រាស	អនុប្រធាន
៦- តំណាងនិយោជក	អនុប្រធាន
៧- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
៨- តំណាងក្រសួងពាណិជ្ជកម្ម	សមាជិក
៩- តំណាងក្រសួងសុខាភិបាល	សមាជិក
១០- តំណាងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល	សមាជិក
១១- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក
១២- តំណាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	សមាជិក
១៣- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក
១៤- តំណាងក្រសួងទេសចរណ៍	សមាជិក
១៥- តំណាងក្រសួងកិច្ចការនារី	សមាជិក
១៦- តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
១៧- តំណាងក្រសួងធនធានទឹក និងឧតុនិយម	សមាជិក
១៨- តំណាងក្រសួងផែនការ	សមាជិក
១៩- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
២០- តំណាងក្រសួងបរិស្ថាន	សមាជិក
២១- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
២២- ប្រធានទីភ្នាក់ងារជាតិមុខរបរ និងការងារ	សមាជិក
២៣- តំណាង ៤រូប របស់និយោជក	សមាជិក
២៤- តំណាង ១រូប របស់សភាពាណិជ្ជកម្ម	សមាជិក
២៥- តំណាង ២រូប របស់នាយោជិត	សមាជិក
២៦- តំណាង ៣រូប ជាអ្នកផ្តល់ការបណ្តុះបណ្តាល	សមាជិក
២៧- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	នាយកប្រតិបត្តិ។

គណៈកម្មាធិការជាតិអាចអញ្ជើញតំណាង ៣រូប របស់អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ចូលរួមបាន។

គណៈកម្មាធិការជាតិនេះ មានអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាលេខាធិការដ្ឋានអចិន្ត្រៃយ៍។

មាត្រា ពីរ..

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ គណៈកម្មាធិការជាតិបណ្តុះបណ្តាល អភិបាលរាជធានី-ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ៨ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ* ✓

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៧៨៤ អនក្រ.បក

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២៦៤ . អនក្រ. បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **គាន់ គាល់** នាយកអង្គការ Room to Read ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់ថវិកាចំនួន ៧៤៥.១៨០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារបណ្ណាល័យថ្មី ចំនួន១៤ខ្នង បណ្ណាល័យមធ្យមក្នុងបន្ទប់រៀន ៨៦បន្ទប់ បណ្ណាល័យចល័តជាទូ ៦៩ទូ និងបណ្ណាល័យជ្រុងថ្នាក់០៥សាលា ស្មើនឹង២០ទូ និងសម្ភារៈបរិក្ខារសម្រាប់បណ្ណាល័យជូនដល់សាលារៀននៅខេត្តកំពង់ធំ ។

មាត្រា២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចមាត្រា១ និងមាត្រា២

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៤ សសរ

សេចក្តីសំរេច
ស្តីពី
ការបង្កើតគណៈបញ្ជាការ ការពារសន្តិសុខ គោលដៅ ទីស្តីការគណៈរដ្ឋមន្ត្រី និងទីស្តីការនាយករដ្ឋមន្ត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/ ១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា ។

សម្រេច

ប្រការ ១ ៖ បង្កើតគណៈបញ្ជាការ ការពារសន្តិសុខ គោលដៅ ទីស្តីការគណៈរដ្ឋមន្ត្រី និង ទីស្តីការនាយករដ្ឋមន្ត្រី ដែលមានសមាសភាពដូចខាងក្រោម ៖

១- ឯកឧត្តម នាយឧត្តមសេនីយ៍ **ប្រាក់ សុខុន** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាប្រធាន

២- ឯកឧត្តម នាយឧត្តមសេនីយ៍ **ហ៊ីង ប៊ុនហៀង** អគ្គមេបញ្ជាការរងនៃ ខ.ភ.ម និងជាមេបញ្ជាការ មេបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធាន

៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក **យូ ស៊ិនឡុង** អគ្គស្នងការរងនគរបាលជាតិ ជាអនុប្រធាន

៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក	ហ៊ុយ ពិសិដ្ឋ	អនុរដ្ឋលេខាធិការក្រសួងការពារជាតិ ប្រចាំការដឹកនាំបញ្ជាបញ្ជាការដ្ឋានអង្គរក្ស ជាអនុប្រធានអចិន្ត្រៃយ៍
៥- ឯកឧត្តម ឧត្តមសេនីយ៍ឯក	តាន់ បញ្ញាវុធ	នាយករងខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាអនុប្រធានអចិន្ត្រៃយ៍ ទទួលបន្ទុកការងារសន្តិសុខនៃអគារសន្តិភាព
៦- ឯកឧត្តម	សូស យ៉ារ៉ា	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាអនុប្រធានទទួលសម្របសម្រួលការងារទូទៅ គ្រប់គ្រងបច្ចេកទេសអគារទាំងពីរ និង ទទួលបន្ទុកការងារសន្តិសុខនៃអគារមិត្តភាព
៧- ឯកឧត្តម	ប៉ា សុជាតិវង្ស	អភិបាលរងរាជធានីភ្នំពេញ ជាអនុប្រធានទទួលការងារក្តាប់ព័ត៌មានទូទៅ ទប់ស្កាត់ដោះស្រាយរាល់បាតុភាព និងពាល់ពាក្យបណ្តឹងតវ៉ាផ្សេងៗ
៨- ឯកឧត្តម	ប៊ូន លីមហេង	អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី ជាសមាជិកទទួលបន្ទុកការងារធានាផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
៩- ឯកឧត្តម	សេង ទៀង	ជំនួយការសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី ជាសមាជិកទទួលការងារសម្របសម្រួលទូទៅ និងផ្គត់ផ្គង់
១០- ឯកឧត្តម ឧត្តមសេនីយ៍ឯក	ណុប រតនា	នាយរងសេនាធិការចំរុះ នៃ ខ.ភ.ម ជាសមាជិក
១១- ឯកឧត្តម ឧត្តមសេនីយ៍ទោ	ហ៊ិន ម៉ាណែត	មេបញ្ជាការរងបញ្ជាការដ្ឋានកងទ័ពជើងគោក នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកអចិន្ត្រៃយ៍ទទួលផែនសន្តិសុខការពារភៀកសម្តេចតេជោ និងលោកជំទាវបណ្ឌិត និងអន្តរាគមន៍ពិសេស
១២- ឯកឧត្តម ឧត្តមសេនីយ៍ឯក	ចៅ តុល	នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការរងបញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក
១៣- ឯកឧត្តម ឧត្តមសេនីយ៍ឯក	ឡៅ សារុន	មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក
១៤- ឯកឧត្តម ឧត្តមសេនីយ៍ឯក	វង្ស ពិសេន	មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស ជាសមាជិកទទួលការងារអន្តរាគមន៍
១៥- ឯកឧត្តម ឧត្តមសេនីយ៍ទោ	ព្រហ្ម ឌិន	មេបញ្ជាការយោធភូមិភាគពិសេស ជាសមាជិក ទទួលការងារអន្តរាគមន៍
១៦- ឯកឧត្តម ឧត្តមសេនីយ៍ទោ	ភោគ ចន្ថា	មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិកអចិន្ត្រៃយ៍ ទទួលបន្ទុកដឹកនាំកម្លាំងការពារសន្តិសុខអគារទាំងពីរ និងបរិវេណទាំងមូលនៃទីស្តីការគណៈរដ្ឋមន្ត្រី

១៧- ឯកឧត្តម ឧត្តមសេនីយ៍ទោ **អ៊ុង សារិទ្ធ** មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក ទទួលផែនអន្តរាគមន៍

១៨- ឯកឧត្តម ឧត្តមសេនីយ៍ទោ **សុខ ចារុណ្ណ** មេបញ្ជាការរង បញ្ជាការដ្ឋានអង្គរក្ស ជាសមាជិក ទទួលផែនសន្តិសុខផ្ទាល់សម្តេចតេជោ និងលោកជំទាវបណ្ឌិត

១៩- ឯកឧត្តម ឧត្តមសេនីយ៍ទោ **យ៉ា គីមអ៊ី** មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ ជាសមាជិក

២០- ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ទូច ណារ៉ុថ** ស្នងការនគរបាលរាជធានីភ្នំពេញ ជាសមាជិក

២១- ឯកឧត្តម ឧត្តមសេនីយ៍ត្រី **ជឹម សារឿន** នាយករង នាយកដ្ឋាននគរបាលការពារ ជាសមាជិក

ប្រការ ២ ៈ គណៈបញ្ជាការនេះមានភារកិច្ចដូចខាងក្រោម ៖

- ការពារសន្តិសុខ សុវត្ថិភាព ក្នុង និង ជុំវិញ អគារសន្តិភាព និង អគារមិត្តភាពទាំងមូល ២៤ម៉ោង លើ ២៤ម៉ោង
- គ្រប់គ្រងកងកម្លាំងប្រដាប់អាវុធទាំងអស់ដែលមានភារកិច្ចទទួលខុសត្រូវការពារក្នុងអគារសន្តិភាព និង អគារមិត្តភាព
- ពិនិត្យជាតិផ្ទុះ ជាតិពុល ព្រមទាំងផែកឆេះ រាល់ថយន្ត និងសមាសភាព ដែលចូលក្នុងបរិវេណ អគារសន្តិភាព និង អគារមិត្តភាព
- សហការជាមួយគណៈកម្មការគ្រប់គ្រង ប្រើប្រាស់ និងសម្របសម្រួលពិធី និងកិច្ចប្រជុំនានាក្នុងអគារសន្តិភាពដើម្បីសម្របសម្រួលការរៀបចំកិច្ចប្រជុំនានាក្នុងអគារសន្តិភាព និងអគារមិត្តភាព
- សហការជាមួយសមត្ថកិច្ច អាជ្ញាធរដែនដី តាមដានក្តាប់សភាពការណ៍ ព្រមទាំងទប់ស្កាត់រាល់សកម្មភាពភូតកម្ម បាតុកម្ម និង ការតវ៉ាផ្សេងៗ ដែលនាំឲ្យប៉ះពាល់ដល់ការរៀបចំពិធីក្នុងអគារសន្តិភាព និង អគារមិត្តភាព
- ពិនិត្យរាល់ការប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិចសន្តិសុខ នៅក្នុង និង ជុំវិញអគារសន្តិភាព និង អគារមិត្តភាព ។

ប្រការ ៣ ៈ គណៈបញ្ជាការ មានសិទ្ធិប្រើប្រាស់ត្រារបស់ ទីស្តីការគណៈរដ្ឋមន្ត្រី ។

ប្រការ ៤ ៈ អនុប្រធាន និងសមាជិក ត្រូវចូលរួមប្រជុំតាមការអញ្ជើញពីប្រធានគណៈបញ្ជាការ។

ប្រការ ៥ ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសមាជិកគណៈបញ្ជាការដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៥*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ: ១១៩៨ ... សហវ.ប្រក

ប្រកាស
ស្តីពី
ការកែសម្រួលអត្រាពន្ធគយលើទំនិញនាំចូលមួយចំនួន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពី ការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងចំណារដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១០ លើលិខិតលេខ ៧៥៨៣ សហវ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញប្រកាសលេខ ១៣៧៣ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់ឲ្យប្រើប្រាស់តារាងពន្ធគយកម្ពុជាឆ្នាំ ២០១០
- យោងតាមសំណូមពរការងារចាំបាច់

សម្រេច

ប្រការ ១.-

ត្រូវបានកែសម្រួលអត្រាពន្ធគយលើមុខទំនិញផលិតផលគេលសិលានាំចូលចំនួន ១១ បន្ទាត់ពន្ធ នៃតារាងពន្ធគយកម្ពុជាជាធរមាន រួមមាន ៖

- បន្ថយអត្រាពន្ធគយពី ៣៥% មក ១៥% ចំនួន ០៦ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញប្រេងសាំង រថយន្តនៃទីតាំងរងលេខ ២៧១០.១១.១១ ២៧១០.១១.១២ ២៧១០.១១.១៣ ២៧១០.១១.១៤ ២៧១០.១១.១៥ និង ២៧១០.១១.១៦ ។
- បន្ថយអត្រាពន្ធគយពី ១៥% មក 0% ចំនួន ០៣ បន្ទាត់ពន្ធ ចំពោះបណ្តាមុខទំនិញប្រេងម៉ាស៊ូត នៃទីតាំងរងលេខ ២៧១០.១៩.៧១ ២៧១០.១៩.៧២ និង ២៧១០.១៩.៩០ ។
- បន្ថយអត្រាពន្ធគយពី ៧% មក 0% ចំនួន ២ បន្ទាត់ពន្ធ ចំពោះមុខទំនិញប្រេងកាត និង ប្រេងខ្មៅនៃទីតាំងរងលេខ ២៧១០.១៩.១៦ និង ២៧១០.១៩.៧៩ ។

ប្រការ ២.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៣.-

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រម ទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតត្រូវទទួលបន្ទុកចាត់ចែងអនុវត្តតាមខ្លឹមសារប្រកាសនេះឲ្យមាន ប្រសិទ្ធភាព ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១១ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០១០

ឧបនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ទីស្តីការគណៈរដ្ឋមន្ត្រី
  "ដើម្បីជូនជ្រាប"
- អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា
- ដូចប្រការ ៣
  "ដើម្បីអនុវត្ត"
- សភាពាណិជ្ជកម្មកម្ពុជា
  "ដើម្បីជ្រាប និងសុំកិច្ចសហការផ្សព្វផ្សាយ"
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

លេខ ១២៩២..... សហវ-កយ.ប្រក

ក្រសួងយុត្តិធម៌

រាជធានីភ្នំពេញ , ថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១០

ប្រកាសអន្តរក្រសួង
ស្តីពី
ការកំណត់កម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ ០៦ ន.ស.៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែមនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការដំឡើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការកែលំអ និងបំពេញបន្ថែមអនុក្រឹត្យស្តីពីការប្រមូលពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតលេខ ១៤០០ សជណ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១០ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការសម្រេចកំណត់កម្រៃសេវារដ្ឋបាល និងការផ្តល់ប្រាក់ឧបត្ថម្ភជូនក្រសួងយុត្តិធម៌ លើការងារប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស
- បានឃើញប្រកាសលេខ ១៤០៥ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការរៀបចំ និងកិច្ចដំណើរការគណនីនៃរដ្ឋទេយ្យចំណូល
- បានឃើញសារាចរណែនាំលេខ ០១៣ សហវ. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ស្តីពីការគ្រប់គ្រងរដ្ឋទេយ្យចំណូល
- បានឃើញប្រកាសលេខ ១៤៤៨ សហវ. ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ
- តាមតម្រូវការចាំបាច់នៃការងារសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នាពេលបច្ចុប្បន្ន

សម្រេច

ប្រការ ១ : ត្រូវបានអនុញ្ញាតឱ្យក្រសួងយុត្តិធម៌ ប្រមូលចំណូលពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ដែលជាប្រភេទព្រឹត្តិបត្រលេខ ៣ ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ។

ប្រការ ២ : សេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ត្រូវបានបែងចែកជាសេវាធម្មតា និងសេវាឆាប់រហ័ស។ សេវាធម្មតា គឺការផ្តល់ព្រឹត្តិបត្រថ្កោលទោសក្នុងរយៈពេលមិនលើសពី ២០(ម្ភៃ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។ សេវាឆាប់រហ័ស គឺការផ្តល់ព្រឹត្តិបត្រថ្កោលទោសក្នុងរយៈពេល ១២(ដប់ពីរ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃទទួលពាក្យស្នើសុំ។ ការផ្តល់សេវាឆាប់រហ័សនេះ ធ្វើឡើងចំពោះតែករណីចាំបាច់បន្ទាន់ ដែលសាមីជនត្រូវបង្ហាញទឡ្ហីករណ៍បញ្ជាក់អំពីភាពចាំបាច់បន្ទាន់នោះ ទៅតាមលក្ខខណ្ឌដែលកំណត់ដោយក្រសួងយុត្តិធម៌។

ប្រការ ៣ : កម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ត្រូវបានកំណត់ដូចតារាងខាងក្រោម ៖

បរិយាយ	កម្រៃសេវារដ្ឋបាល	
	សេវាធម្មតា	សេវាឆាប់រហ័ស
១- ចំពោះជនជាតិខ្មែរ	១០.០០០រៀល	៤០.០០០រៀល
២- ចំពោះជនជាតិបរទេស	២៥០.០០០រៀល	៥០០.០០០រៀល

ប្រការ ៤ : កម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ដែលបានកំណត់ក្នុងប្រការ ៣ ខាងលើនេះ បានគិតរួមបញ្ចូលទាំងតម្លៃនៃទម្រង់ឯកសារនានាសម្រាប់ការសរសេរបំពេញ ដើម្បីស្នើសុំព្រឹត្តិបត្រថ្កោលទោស។ លើកលែងតែថ្លៃពន្ធតែមប្រិ៍សារពើពន្ធ ដែលជាបន្ទុករបស់សាមីជន ដែលតម្រូវឱ្យបិទសន្លឹកតែមប្រិ៍សារពើពន្ធមានតម្លៃ ១.០០០រៀល នៅលើពាក្យស្នើសុំ និងបិទសន្លឹកតែមប្រិ៍សារពើពន្ធមានតម្លៃ ១.២០០រៀល នៅលើព្រឹត្តិបត្រថ្កោលទោស។

ប្រការ ៥ : ក្រសួងយុត្តិធម៌ ត្រូវបិទផ្សាយជាសាធារណៈអំពីតារាងតម្លៃ ទម្រង់ឯកសារ និងនីតិវិធីដែលត្រូវបំពេញ សម្រាប់ការស្នើសុំព្រឹត្តិបត្រថ្កោលទោស។

ប្រការ ៦ : ការប្រមូលចំណូល ការកត់ត្រាតាមដាន ការបង់ប្រាក់ចំណូលចូលថវិកាជាតិ និងការទទួលខុសត្រូវប្រាក់កាសស្តីពីកម្រៃសេវារដ្ឋបាលនៃការផ្តល់ព្រឹត្តិបត្រថ្កោលទោស ជាភារកិច្ចរបស់រដ្ឋទេយ្យករចំណូលនៃក្រសួងយុត្តិធម៌។ រដ្ឋទេយ្យករចំណូល ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ដាក់ជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដើម្បីពិនិត្យ និងចុះហត្ថលេខា រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី០៧ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

ប្រការ ៧ : រដ្ឋទេយ្យករចំណូល ត្រូវបង់ប្រាក់ចំណូលទាំងស្រុងចូលរតនាគារជាតិ និងធ្វើសលាកប័ត្របង់ចំណូលចូលថវិកាជាតិ ព្រមទាំងធ្វើការកត់ត្រាតាមដានចំណូលនៅក្នុងជំពូក គណនី និងអនុគណនី នៃមាតិកាថវិកាដែលបានកំណត់។

ប្រការ ៨ : អនុញ្ញាតផ្តល់ប្រាក់ឧបត្ថម្ភជូនក្រសួងយុត្តិធម៌ចំនួន ២០%(ម្ភៃភាគរយ) នៃប្រាក់ចំណូលដែលបានបង់ចូលថវិកាជាតិ សម្រាប់ជារង្វាន់លើកទឹកចិត្តផ្តល់ជូនមន្ត្រីរាជការដែលបំពេញការងារគ្រប់គ្រង និងមន្ត្រីដែលអនុវត្តការងារផ្ទាល់។ ការដកប្រាក់ឧបត្ថម្ភនេះ ត្រូវធ្វើឡើងតាមរយៈអាណត្តិបើកប្រាក់ ដោយអនុវត្តនីតិវិធីហិរញ្ញវត្ថុជាធរមាន។

ប្រការ ៩ : បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវចាត់ទុកជានិរាករណ៍។

ប្រការ១០: អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងយុត្តិធម៌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១១ តទៅ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

អង្គ.វង្សវឌ្ឍានៈ

ចម្លងជូន :
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលាខេត្ត និងសាលារាជធានីភ្នំពេញ «ដើម្បីជូនជ្រាប»
- ដូចប្រការ ១០ «ដើម្បីអនុវត្ត»
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០១០-២០៦ ប្រក

ប្រ កា ស

ស្តីពី

ការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់បុគ្គលរាយការណ៍ ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា

ទេសាភិបាល ធនាគារជាតិនៃកម្ពុជា និងជា ប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី២៤ ខែមិថុនាឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៩៥ អនក្រ/តត ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាប្រធានក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- តាមសំណើរបស់លេខាធិការដ្ឋានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា
- យោងតាមស្មារតីនៃអង្គប្រជុំក្រុមប្រឹក្សាភិបាលអង្គភាពស៊ើបការណ៍កម្ពុជា លើកទី៩ ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០

ស ម្រេ ច

ប្រការ ១.- ដែនកំណត់

សម្រាប់គោលបំណងនៃប្រកាសនេះ ពាក្យថា "បុគ្គលរាយការណ៍" សំដៅដល់គ្រឹះស្ថាន និងវិជ្ជាជីវៈដូចខាងក្រោម ដែលមិនស្ថិតក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា និងត្រូវបានហៅថា"បុគ្គលរាយការណ៍" នៅក្នុងច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ៖ ...

ក. គ្រឹះស្ថានមិនមែនធនាគារនិងហិរញ្ញវត្ថុ ដោយរួមបញ្ចូលក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនធានារ៉ាប់រង

ខ. មូលនិធិសោធននិងវិនិយោគ ក្រុមហ៊ុនវិនិយោគ និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិវិនិយោគ

គ. ភ្នាក់ងារអចលនទ្រព្យ អគារ និងដីធ្លី

ឃ. ការិយាល័យប្រៃសណីយ៍ដែលធ្វើប្រតិបត្តិការទូទាត់សងប្រាក់

ង. មេធាវី សារការី គណនេយ្យករ សវនករ ទីប្រឹក្សាវិនិយោគ និងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ នៅពេលដែលអ្នកទាំងនោះត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជនរបស់ខ្លួននូវសកម្មភាពដូចមានចែងក្នុងប្រការ ២ នៃប្រកាសនេះ

ច. កាស៊ីណូ និងស្ថាប័នល្បែងស៊ីសងផ្សេងទៀត

ឆ. អង្គការក្រៅរដ្ឋាភិបាល និងអង្គការមូលនិធិ ដែលធ្វើសកម្មភាពអាជីវកម្ម និងមូលនិធិសប្បុរសធម៌

ជ. ក្រុមហ៊ុនអាណត្តិព្យាបាល និងក្រុមហ៊ុនផ្តល់សេវាផ្សេងៗ

ឈ. គ្រឹះស្ថាន ឬវិជ្ជាជីវៈផ្សេងទៀត កំណត់ដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ប្រការ ២.- សកម្មភាពអាជីវកម្មរបស់បុគ្គលរាយការណ៍

នៅពេលដែល មេធាវី សារការី គណនេយ្យករ សវនករ អ្នកផ្តល់ប្រឹក្សាវិនិយោគនិងអ្នកគ្រប់គ្រងទ្រព្យសកម្ម ត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជនរបស់ខ្លួននូវសកម្មភាពទាំងឡាយ ដូចខាងក្រោម ៖

ក. ទទួលទិញ និងលក់អចលនទ្រព្យ អគារ និងដីធ្លី

ខ. គ្រប់គ្រងសាច់ប្រាក់ មូលបត្រ ឬទ្រព្យសកម្មផ្សេងទៀតរបស់អតិថិជន

- គ្រប់គ្រងគណនីធនាគារ ឬគណនីមូលបត្រ
- ចូលរួមបង្កើតប្រតិបត្តិការ ឬគ្រប់គ្រងក្រុមហ៊ុន

គ. បង្កើតប្រតិបត្តិការ ឬគ្រប់គ្រងនីតិបុគ្គល ឬកិច្ចសម្របសម្រួល និងការទិញនិងលក់អង្គភាពអាជីវកម្ម

ឃ. នៅពេលដែល ក្រុមហ៊ុនអាណត្តិព្យាបាល ត្រៀមអនុវត្ត ឬអនុវត្តជំនួសអតិថិជននូវសកម្មភាពទាំងឡាយ ដូចខាងក្រោមៈ

- ធ្វើសកម្មភាពជាភ្នាក់ងារបង្កើតនីតិបុគ្គលនោះ
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជានាយក ឬជាលេខាធិការរបស់ក្រុមហ៊ុន ឬជាភាគទុនិកនៃក្រុមហ៊ុនសហកម្មសិទ្ធិ ឬតួនាទីប្រហាក់ប្រហែលទាក់ទងជាមួយនីតិបុគ្គលផ្សេងទៀត

- ផ្តល់ទីស្នាក់ការផ្លូវការ អាសយដ្ឋាន ឬទីតាំងអាជីវកម្ម អាសយដ្ឋានទំនាក់ទំនង ឬរដ្ឋបាល សម្រាប់ក្រុមហ៊ុនសហកម្មសិទ្ធិ ភាគទុនិក ឬនីតិបុគ្គលដទៃទៀត ឬការសម្របសម្រួលដទៃទៀត
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុនអាណត្តិព្យាបាល
- ធ្វើសកម្មភាព ឬរៀបចំឱ្យបុគ្គលផ្សេងធ្វើសកម្មភាពជាភាគទុនិក ដែលត្រូវបានតែងតាំងជំនួសឱ្យបុគ្គលដទៃ ។

ប្រការ ៣.- គោលការណ៍ទទួលស្គាល់អតិថិជន

បុគ្គលរាយការណ៍ ត្រូវបង្កើតគោលការណ៍ និងនីតិវិធីទទួលស្គាល់អតិថិជន ហើយត្រូវមានវិធានការសមស្រប រួមមាន សាវតារហានិភ័យនៅក្នុងគោលការណ៍ និងនីតិវិធីផ្ទៃក្នុងរបស់ខ្លួន ដើម្បីកំណត់ហានិភ័យផ្សេងៗ ដែលបានបង្កើតឡើងដោយប្រភេទអតិថិជននីមួយៗ ឬអតិថិជនជារូបវន្តបុគ្គលនីមួយៗ ។

ប្រការ ៤.- ការកំណត់សាវតារហានិភ័យ

៤.១ ក្នុងការកំណត់សាវតារហានិភ័យតាមប្រភេទអតិថិជននីមួយៗ ឬតាមអតិថិជនជារូបវន្តបុគ្គលនីមួយៗ យ៉ាងហោចណាស់ បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ទៅលើកត្តាមួយចំនួនដូចខាងក្រោម ៖

- ប្រភពដើមរបស់អតិថិជន និងទីតាំងអាជីវកម្ម
- សាវតារនិងបុគ្គលិកលក្ខណៈពិសេសរបស់អតិថិជន
- លក្ខណៈអាជីវកម្មរបស់អតិថិជន
- រចនាសម្ព័ន្ធកម្មសិទ្ធិសម្រាប់អតិថិជនជាក្រុមហ៊ុន និង
- ព័ត៌មានផ្សេងៗដែលអាចបញ្ជាក់ថា អតិថិជនមានហានិភ័យខ្ពស់។

៤.២ បន្ទាប់ពីទទួលស្គាល់អតិថិជនជាលើកដំបូង បុគ្គលរាយការណ៍ត្រូវតាមដានសកម្មភាពគណនីអតិថិជនជាប្រចាំ ដើម្បីធានាថាសកម្មភាពគណនីនេះសមស្របទៅនឹងសាវតាររបស់អតិថិជន ។ ក្នុងករណីមានភាពមិនស្របគ្នា បុគ្គលរាយការណ៍ត្រូវវាយតម្លៃឡើងវិញថា ជាអតិថិជនមានហានិភ័យខ្ពស់ ។

ប្រការ ៥.- ការហាមឃាត់គណនីអនាមិក និងគណនីបតិរូបកម្ម

បុគ្គលរាយការណ៍ដែលបើកគណនីឱ្យអតិថិជន ត្រូវធានាថា ការបើកគណនីត្រូវតែមានម្ចាស់គណនី និងត្រូវរក្សាទុកឈ្មោះគណនីគ្រប់ពេលទាំងអស់ ។ លើសពីនេះបុគ្គលរាយការណ៍ត្រូវសម្គាល់អត្តសញ្ញាណអតិថិជន ដូចមានចែងនៅក្នុង ប្រការ ៧ និង ប្រការ ៨ នៃប្រកាសនេះ ហើយត្រូវធានាថា គ្មានអតិថិជនណាម្នាក់ត្រូវបានអនុញ្ញាតឱ្យបង្កើតទំនាក់ទំនង ឬធ្វើប្រតិបត្តិការគណនីណាមួយដែលមានឈ្មោះប្រឌិត មិនត្រឹមត្រូវ ឬក្លែងក្លាយ ។

ប្រការ ៦.- ការយកចិត្តទុកដាក់ស្គាល់អតិថិជន

៦.១ បុគ្គលរាយការណ៍ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងទាមទារឱ្យមានភស្តុតាងគ្រប់គ្រាន់ព្រមទាំងកត់ត្រាទុកឱ្យបានត្រឹមត្រូវនូវអត្តសញ្ញាណ និងលក្ខណៈគតិយុត្តិរបស់បុគ្គលដែលស្នើសុំធ្វើប្រតិបត្តិការ ។ ភស្តុតាងទាំងនេះត្រូវតែជាឯកសារដែលអាចជឿជាក់បាន ។

៦.២ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវធ្វើឡើងនៅពេល ៖

- បង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ដូចជា ការបើកគណនី ការផ្តល់សេវាប្រអប់សុវត្ថិភាព ឬការចុះកិច្ចសន្យាអាជីវកម្មផ្សេងទៀត
- អនុវត្តប្រតិបត្តិការដែលកើតឡើងតែមួយដង ឬម្តងម្កាល ដែលមានទឹកប្រាក់លើសពី សែសិបលានរៀល (៤០.០០០.០០០៛) ឬដប់ពាន់ដុល្លារអាមេរិក (១០.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត) ការផ្ទេរតាមប្រព័ន្ធអេឡិកត្រូនិក ដែលមានទឹកប្រាក់លើសពី បួនលានរៀល (៤.០០០.០០០រៀល) ឬមួយពាន់ដុល្លារអាមេរិក (១.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត)
- ដកយកសាច់ប្រាក់ឈ្នះពីការលេងល្បែង ដែលមានតម្លៃលើសពី សែសិបលានរៀល (៤០.០០០.០០០៛) ឬដប់ពាន់ដុល្លារអាមេរិក (១០.០០០$ ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត)
- បុគ្គលរាយការណ៍សង្ស័យថា ជាការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឬ
- បុគ្គលរាយការណ៍សង្ស័យពីភាពមិនត្រឹមត្រូវ ឬភាពគ្រប់គ្រាន់នៃព័ត៌មានដែលបានទទួលកន្លងមក។

៦.៣ ក្នុងការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន បុគ្គលរាយការណ៍ យ៉ាងហោចណាស់ត្រូវ ៖

- សម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់បុគ្គលដែលអនុវត្តប្រតិបត្តិការដោយប្រើប្រាស់ប្រភពឯកសារ ទិន្នន័យ ឬព័ត៌មានដែលឯករាជ្យ នឹងអាចជឿជាក់បានស្របតាមប្រការ ៨ ឬ ៩ នៃប្រកាសនេះ
- កំណត់ថាអតិថិជនកំពុងធ្វើប្រតិបត្តិការជំនួសបុគ្គល ឬអត្ថគាហកណាមួយ
- ស្វែងយល់ពីអត្ថគាហក និងរចនាសម្ព័ន្ធត្រួតពិនិត្យរបស់អតិថិជន (អត្ថគាហកត្រូវបានផ្តល់និយមន័យនៅក្នុងប្រការ ៩ នៃប្រកាសនេះ)
- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន និងពិនិត្យពិច័យជាបន្តបន្ទាប់ដើម្បីធានាថា ព័ត៌មានដែលបានទទួលត្រូវបានធ្វើបច្ចុប្បន្នកម្ម និងសមស្របជាមួយចំណេះដឹងរបស់បុគ្គលរាយការណ៍អំពីអាជីវកម្ម និងសាវតារហានិភ័យរបស់អតិថិជន និងប្រសិនបើចាំបាច់ត្រូវដឹងពីប្រភពមូលនិធិ ។

៦.៤ ការបដិសេធរបស់អតិថិជនក្នុងការផ្តល់ព័ត៌មាន និងមិនសហការក្នុងដំណើរការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់បុគ្គលរាយការណ៍អាចចាត់ទុកជាការសង្ស័យ។

៦.៥ បុគ្គលរាយការណ៍ មិនត្រូវបើកគណនី ផ្តើមទំនាក់ទំនងអាជីវកម្ម ឬធ្វើប្រតិបត្តិការ ឬក្នុងករណីដែលទំនាក់ទំនងអាជីវកម្មមានស្រាប់ បុគ្គលរាយការណ៍ត្រូវបញ្ឈប់ទំនាក់ទំនងទាំងនោះ ប្រសិនបើ អតិថិជនមិនអនុវត្តតាមកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជន ។ ស្ថានការណ៍បែបនេះ ត្រូវកត់ត្រាក្នុងរបាយការណ៍សង្ស័យដែលត្រូវផ្ញើជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

ប្រការ៧.- អតិថិជនជាឯកត្តបុគ្គល

៧.១ ក្នុងការបង្កើតទំនាក់ទំនងអាជីវកម្មជាមួយអតិថិជនជាឯកត្តបុគ្គល បុគ្គលរាយការណ៍ត្រូវប្រមូលព័ត៌មានដូចជាឈ្មោះ ថ្ងៃខែឆ្នាំកំណើត លេខអត្តសញ្ញាណប័ណ្ណ លេខលិខិតឆ្លងដែន លេខយោងឯកសារអត្តសញ្ញាណអាជីវកម្ម/មុខរបរ សញ្ជាតិ និងអាសយដ្ឋាន ។

៧.២ បុគ្គលរាយការណ៍ តម្រូវឱ្យឯកត្តបុគ្គលផ្តល់ឯកសារដើម និងថតចម្លងទុកនូវឯកសារមួយ ឬច្រើនជាង ដូចខាងក្រោម ៖

- អត្តសញ្ញាណប័ណ្ណ
- លិខិតឆ្លងដែន ឬ
- ឯកសារបញ្ជាក់ពីអត្តសញ្ញាណប្រហាក់ប្រហែលផ្សេងៗទៀត ដែលចេញផ្សាយដោយអាជ្ញាធរមានសមត្ថកិច្ច ដោយមានភ្ជាប់មកជាមួយនូវរូបថតរបស់អតិថិជន ។

ប្រការ ៨.- អតិថិជនជាក្រុមហ៊ុន

៨.១ ក្នុងការបង្កើតទំនាក់ទំនងជាមួយអតិថិជនជាក្រុមហ៊ុន បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យក្រុមហ៊ុនឬអាជីវកម្ម ផ្តល់ឯកសារដើម និងថតចម្លងទុកឯកសារដូចខាងក្រោម ៖

- អនុស្សរណៈ លក្ខន្តិកៈ វិញ្ញាបនបត្រក្រុមហ៊ុន ក្រុមហ៊ុនសហកម្មសិទ្ធិ
- ឯកសារអត្តសញ្ញាណ របស់ក្រុមប្រឹក្សាភិបាល នាយក ភាគទុនិក ដៃគូ
- សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬនាយក
- លិខិតផ្ទេរសិទ្ធិដល់បុគ្គលណាម្នាក់ជាតំណាងឱ្យក្រុមហ៊ុនឬអាជីវកម្ម
- សិទ្ធិអំណាច ឬការអនុញ្ញាតឱ្យធ្វើអាជីវកម្ម ។

៨.២ លើសពីនេះ បុគ្គលរាយការណ៍ត្រូវស្រាវជ្រាវ ឬសាកសួរពីប្រវត្តិរបស់ក្រុមហ៊ុនឬអាជីវកម្មដើម្បីធានាថាក្រុមហ៊ុនមិនទាន់ត្រូវបាន ឬមិនស្ថិតនៅក្នុងដំណើរការជំរះបញ្ជី ឬមានបញ្ហាលំបាកអ្វីឡើយ ។

៨.៣ បុគ្គលរាយការណ៍ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនី ដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល ។ ពេលផ្លាស់ប្តូរហត្ថលេខី បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ដើម្បីធានាថាហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ ។

៨.៤ ដើម្បីផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបាន បុគ្គលរាយការណ៍ត្រូវពិនិត្យមើលការចុះបញ្ជីរបស់ក្រុមហ៊ុនឬអាជីវកម្ម ដើម្បីបញ្ជាក់ភាពត្រឹមត្រូវនៃព័ត៌មានដែលទទួលបានអំពីអត្តសញ្ញាណរបស់ក្រុមហ៊ុនឬអាជីវកម្ម និងអភិបាល ម្ចាស់ភាគទុនិក និងនាយកនៃក្រុមហ៊ុននោះ ។

៨.៥ នៅពេលដែលអតិថិជន ឬម្ចាស់គ្រប់គ្រងភាគទុនិកជាសាជីវកម្មដែលមានកាតព្វកិច្ចបើកចំហព័ត៌មាន នៅក្នុងទីផ្សារភាគហ៊ុនដែលទទួលស្គាល់នោះ អត្តសញ្ញាណរបស់ភាគទុនិកនៃសាជីវកម្មពុំចាំបាច់ត្រូវសម្គាល់ ឬផ្ទៀងផ្ទាត់ឡើយ។

៨.៦ បុគ្គលរាយការណ៍ ក៏ត្រូវដឹងពីរចនាសម្ព័ន្ធនិងកម្មសិទ្ធិរបស់អតិថិជនជាក្រុមហ៊ុន និងកំណត់ប្រភពទុនរបស់ក្រុមហ៊ុនឬអាជីវកម្ម ។ ប្រការនេះនឹងជួយឱ្យបុគ្គលរាយការណ៍រកឃើញការសង្ស័យណាមួយដែលទាក់ទងនឹងការផ្លាស់ប្តូររចនាសម្ព័ន្ធឬភាពជាម្ចាស់កម្មសិទ្ធិរបស់ក្រុមហ៊ុន ឬការផ្លាស់ប្តូរសាវតារអតិថិជន និងសកម្មភាពតាមរយៈគណនីរបស់ក្រុមហ៊ុនឬអាជីវកម្ម ។

ប្រការ ៩.- អត្ថគាហក

បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនឱ្យបានហ្មត់ចត់ ដូចដែលបានអនុវត្តចំពោះអតិថិជនជាឯកត្តបុគ្គលនៅពេលសង្ស័យថា មានប្រតិបត្តិការណាមួយត្រូវបានធ្វើឡើងក្នុងនាមអត្ថគាហកបន្ថែមលើអតិថិជនដែលកំពុងធ្វើប្រតិបត្តិការនោះ ។ អត្ថគាហកជាបុគ្គលដែលបានកាន់កាប់ផ្ដាច់មុខ ឬត្រួតពិនិត្យអតិថិជនណាម្នាក់ ឬជាបុគ្គលត្រូវបានធ្វើប្រតិបត្តិការជំនួស ។ អត្ថគាហកក៏រាប់បញ្ចូលនូវបុគ្គលដែលកាន់កាប់ផ្ដាច់មុខលើនីតិបុគ្គល ឬការរៀបចំចាត់ចែងណាមួយផងដែរ ។

ប្រការ ១០.- អង្គការក្រៅរដ្ឋាភិបាល និង មូលនិធិ

១០.១ បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យអង្គការក្រៅរដ្ឋាភិបាល ឬមូលនិធិ ដែលមានទំនាក់ទំនងអាជីវកម្មផ្ដល់ឯកសារបង្កើតស្ថាប័ន ឬឯកសារប្រហាក់ប្រហែលផ្សេងទៀត ដើម្បីធានាថា អង្គការក្រៅរដ្ឋាភិបាល និងមូលនិធិនោះត្រូវបានបង្កើត និងចុះបញ្ជីបានត្រឹមត្រូវ ។

១០.២ បុគ្គលរាយការណ៍ ត្រូវផ្ទៀងផ្ទាត់អត្តសញ្ញាណនៃគ្រប់ហត្ថលេខីលើគណនី ដោយយោងទៅតាមការយកចិត្តទុកដាក់ស្គាល់អតិថិជនជាឯកត្តបុគ្គល ។ ពេលផ្លាស់ប្តូរហត្ថលេខី បុគ្គលរាយការណ៍ត្រូវយកចិត្តទុកដាក់ដើម្បីធានាថាហត្ថលេខាបច្ចុប្បន្នទាំងអស់ត្រូវបានផ្ទៀងផ្ទាត់ហើយ ។

១០.៣ បុគ្គលរាយការណ៍ ត្រូវស្វែងយល់អំពីការត្រួតពិនិត្យ និងការសម្រេចរបស់អង្គការក្រៅរដ្ឋាភិបាល ឬមូលនិធិ និងការប្រើប្រាស់ប្រភពមូលនិធិ។

ប្រការ ១១.- គណនីអាណត្តិព្យាបាល និង គណនីតំណាង

១១.១ បុគ្គលរាយការណ៍ ត្រូវកំណត់ថាអតិថិជនកំពុងតំណាងឱ្យបុគ្គលផ្សេងទៀត ដែលជាអ្នកទទួលអាណត្តិព្យាបាល អ្នកតំណាង ឬភ្នាក់ងារ ។

១១.២ បុគ្គលរាយកាណ៍ ត្រូវចាត់វិធានការសមស្រប ដើម្បីឱ្យដឹងពីម្ចាស់កម្មសិទ្ធិ រចនាសម្ព័ន្ធគ្រប់គ្រង និងទំនាក់ទំនងក្នុងចំណោមភាគីពាក់ព័ន្ធផ្សេងៗក្នុងការកាន់កាប់គណនីអាណត្តិព្យាបាល ឬគណនីតំណាង និងត្រូវប្រមូលភស្តុតាងឱ្យបានគ្រប់គ្រាន់ស្តីពីអត្តសញ្ញាណរបស់អ្នកទូទាត់ អ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងហត្ថលេខី ដែលទទួលបានការអនុញ្ញាត អ្នកគ្រប់គ្រង និងអត្ថគាហក ។

១១.៣ បុគ្គលរាយការណ៍ ត្រូវធានាថា កាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជន ត្រូវបានបំពេញសម្រាប់អត្ថគាហក នៅពេលបង្កើតគណនីអាណត្តិព្យាបាល ឬគណនីតំណាង។

១១.៤ បុគ្គលរាយការណ៍ ត្រូវតម្រូវឱ្យមានការធានាជាលាយលក្ខណ៍អក្សរពី អ្នកទទួលអាណត្តិព្យាបាល ឬអ្នកតំណាងថា ភស្តុតាងស្តីពីអត្តសញ្ញាណរបស់អត្ថគាហកត្រូវបានប្រមូល កត់ត្រា និងរក្សាទុក ហើយអ្នកអាណត្តិព្យាបាល ឬអ្នកតំណាងនោះពេញចិត្តនឹងប្រភពមូលនិធិ ។ លើសពីនេះ ព័ត៌មានស្តីពីអត្តសញ្ញាណទាំងនេះចាំបាច់ត្រូវផ្តល់ឱ្យជាបន្ទាន់ តាមការស្នើសុំរបស់បុគ្គលរាយការណ៍ ។

ប្រការ ១២.- គណនីអតិថិជន

បុគ្គលរាយការណ៍ ត្រូវដឹងអំពីប្រតិបត្តិការគណនីអតិថិជន តាមរយៈមេធាវី និងគណនេយ្យករ ដែលបណ្តាលឱ្យមានការបារម្ភ ហើយត្រូវរាយការណ៍ពីប្រតិបត្តិការទាំងឡាយដល់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ប្រសិនបើមានការសង្ស័យណាមួយកើតឡើង ។

ប្រការ ១៣.- ក្រុមហ៊ុនសម្បក (Shell Companies)

បុគ្គលរាយការណ៍ មិនត្រូវបង្កើតទំនាក់ទំនង ឬធ្វើអាជីវកម្មជាមួយក្រុមហ៊ុនដែលមិនធ្វើសកម្មភាពអាជីវកម្ម ឬពុំមានរូបភាពអាជីវកម្មនៅក្នុងប្រទេស ប៉ុន្តែប្រតិបត្តិការហិរញ្ញវត្ថុអាចត្រូវបានធ្វើឡើងតាមរយៈក្រុមហ៊ុនដែលជានីតិបុគ្គលទាំងនោះ ។

ប្រការ ១៤.~ ការពឹងផ្អែកលើអន្តរការី ឬតតិយភាគី សម្រាប់ការយកចិត្តទុកដាក់ស្គាល់អតិថិជន ឬ អាជីវកម្ម

១៤.១ បុគ្គលរាយការណ៍ ត្រូវប្រុងប្រយ័ត្ន និងធានាថា មិនធ្វេសប្រហែស និងមិនពឹងផ្អែកទាំងស្រុងលើការយកចិត្តទុកដាក់ស្គាល់អតិថិជន ដែលធ្វើឡើងដោយអន្តរការី ឬតតិយភាគី ។ ការយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែជាការទទួលខុសត្រូវចុងក្រោយរបស់បុគ្គលរាយការណ៍ ។

១៤.២ បុគ្គលរាយការណ៍ ត្រូវប្រាកដថា អន្តរការី ៖

- អនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន ដោយការសម្គាល់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ថា ប្រភពឯកសារទិន្នន័យ ឬព័ត៌មាន មានភាពឯករាជ្យ និងអាចជឿជាក់បាន
- សម្គាល់អត្តសញ្ញាណអត្ថគាហក ហើយចំពោះអតិថិជនជាក្រុមហ៊ុនត្រូវយល់ដឹងពីភាគទុនិក និងការគ្រប់គ្រង
- យល់ពីគោលបំណង និងលក្ខណៈអាជីវកម្ម
- មានប្រព័ន្ធសម្រាប់បុគ្គលរាយការណ៍ដែលទទួលបានឯកសារ អត្តសញ្ញាណទិន្នន័យ ដោយពុំមានការពន្យារពេល
- អនុញ្ញាតឱ្យបុគ្គលរាយការណ៍ត្រួតពិនិត្យជាប្រចាំសារឡើងវិញ ដើម្បីផ្ទៀងផ្ទាត់ការយកចិត្តទុកដាក់ស្គាល់អតិថិជន និង
- ត្រូវបានធ្វើបញ្ញត្តិកម្ម និងត្រួតពិនិត្យយ៉ាងត្រឹមត្រូវដោយអាជ្ញាធរពាក់ព័ន្ធអំពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ប្រការ ១៥.~ អតិថិជនមិនជួបផ្ទាល់មុខ

១៥.១ បុគ្គលរាយការណ៍ ត្រូវយកចិត្តទុកដាក់ជាពិសេសក្នុងការបង្កើត និងធ្វើអាជីវកម្មមិនជួបផ្ទាល់មុខ ហើយអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនតាមរយៈការប្រាស្រ័យផ្ទាល់ ឬតាមរយៈអន្តរការី ដូចដែលបានតម្រូវដោយប្រការ ១៤ នៃប្រកាសនេះ មុននឹងបង្កើតទំនាក់ទំនងជាមួយអតិថិជនរបស់ខ្លួន ។

១៥.២ បុគ្គលរាយការណ៍ ក៏ត្រូវបានតម្រូវឱ្យអនុវត្តយន្តការតាមដាន និងរាយការណ៍ ដើម្បីសម្គាល់អត្តសញ្ញាណសក្តានុពលនៃសកម្មភាពសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

ប្រការ ១៦.~ បុគ្គលពាក់ព័ន្ធនយោបាយ

១៦.១ ក្នុងដំណើរការអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជន បុគ្គលរាយកាណ៍ត្រូវពិនិត្យមើលអតិថិជនបច្ចុប្បន្ននិងថ្មីៗ ដើម្បីឱ្យដឹងថាអតិថិជនជាបុគ្គលពាក់ព័ន្ធ ឬពុំពាក់ព័ន្ធនយោបាយ ដូចមានចែងនៅ ៧៨

ក្នុងមាត្រា ៣ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ បុគ្គលរាយកាណ៍ត្រូវប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ពីអតិថិជននោះ និងត្រូវស្វែងរកព័ត៌មានដែលមានជាសាធារណៈ ដើម្បីកំណត់ហានិភ័យនៃការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។

១៦.២ ខណៈដែលបុគ្គលពាក់ព័ន្ធនយោបាយត្រូវបានសម្គាល់អត្តសញ្ញាណ បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីកំណត់ពីប្រភពទ្រព្យសម្បត្តិ និងមូលនិធិរបស់បុគ្គលនោះ ។

១៦.៣ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់បុគ្គលរាយការណ៍ត្រូវតែជាអ្នកសម្រេចក្នុងការចូលរួម ឬបន្តទំនាក់ទំនងអាជីវកម្មជាមួយបុគ្គលពាក់ព័ន្ធនយោបាយ ។

១៦.៤ បុគ្គលរាយការណ៍ ត្រូវបង្កើតសាវតារហានិភ័យនៃបុគ្គលពាក់ព័ន្ធនយោបាយម្នាក់ៗ ដោយផ្អែកលើព័ត៌មានដែលប្រមូលបានពីអតិថិជននិងការស្រាវជ្រាវឯករាជ្យ ព្រមទាំងយល់ពីលក្ខណៈនៃទំនាក់ទំនងអាជីវកម្ម និងសកម្មភាពប្រតិបត្តិការ ។ បុគ្គលរាយការណ៍ត្រូវតាមដានជាប្រចាំនូវទំនាក់ទំនង និងសកម្មភាពទប់ទល់ហានិភ័យ និងបញ្ហាដែលកើតឡើងពីដំណើរការត្រួតពិនិត្យ ត្រូវរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់ និងអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បើចាំបាច់ ។

ប្រការ ១៧.- អតិថិជនមានហានិភ័យខ្ពស់ផ្សេងទៀត

១៧.១ បុគ្គលរាយការណ៍ ត្រូវលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជនចំពោះអតិថិជនមានហានិភ័យខ្ពស់ រួមទាំងអតិថិជនជាបុគ្គលពាក់ព័ន្ធនយោបាយ ដើម្បីធានាថាបុគ្គលរាយកាណ៍មិនត្រូវបានបំភាន់ដោយអ្នកសម្អាតប្រាក់និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្ម ។

១៧.២ ការលើកកម្ពស់ការយកចិត្តទុកដាក់ស្គាល់អតិថិជន យ៉ាងហោចណាស់ត្រូវមាន ៖

- ព័ត៌មានលម្អិតបន្ថែមទៀតពីអតិថិជន ជាពិសេសគោលបំណងនៃប្រតិបត្តិការ និងប្រភពនៃមូលនិធិ
- ការស្រាវជ្រាវឯករាជ្យ និងរកប្រភពព័ត៌មានបន្ថែមអំពីអតិថិជន និង
- ការអនុមតិពីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ។

ប្រការ ១៨.- គណនីមានស្រាប់

១៨.១ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការចាំបាច់ ដើម្បីធានាថា កំណត់ត្រានៃអតិថិជនមានស្រាប់នៅតែធ្វើបច្ចុប្បន្នកម្មនិងមានភាពពាក់ព័ន្ធ ។ លើសពីនេះ បុគ្គលរាយការណ៍ត្រូវប្រមូលភស្តុតាងបន្ថែមស្តីពីអត្តសញ្ញាណអតិថិជនមានស្រាប់ប្រសិនបើចាំបាច់ ដើម្បីធានាអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនស្របតាមបទដ្ឋាន ដែលបានកំណត់ដោយប្រកាសនេះ ។

១៨.២ បុគ្គលរាយការណ៍ ត្រូវអនុវត្តការពិនិត្យឡើងវិញឱ្យបានទៀងទាត់លើកំណត់ត្រាមានស្រាប់របស់អតិថិជន ។ ការពិនិត្យឡើងវិញនេះ យ៉ាងហោចណាស់ធ្វើឡើងនៅពេល ៖

- ប្រតិបត្តិការសំខាន់ៗកើតឡើង
- មានការផ្លាស់ប្តូរសំខាន់ៗនៅក្នុងគណនីដែលមានសកម្មភាព
- មានការផ្លាស់ប្តូរបទដ្ឋាននៃការរៀបចំឯកសាររបស់អតិថិជនយ៉ាងច្រើន ឬ
- ព័ត៌មានដែលទទួលបានពីអតិថិជនពុំគ្រប់គ្រាន់ ។

១៨.៣ ប្រសិនបើគ្មានព្រឹត្តិការណ៍ដូចខាងលើកើតឡើង បុគ្គលរាយការណ៍ចាំបាច់ត្រូវពិចារណាដោយផ្អែកលើការវាយតម្លៃហានិភ័យ និងត្រូវប្រមូលព័ត៌មានបន្ថែមពីអតិថិជនមានស្រាប់ ដែលចាត់ទុកថាមានហានិភ័យ ឱ្យស្របតាមបទដ្ឋានបច្ចុប្បន្នរបស់បុគ្គលរាយការណ៍ ។

ប្រការ ១៩.- ការរក្សាទុកឯកសារកត់ត្រា

១៩.១ បុគ្គលរាយការណ៍ ត្រូវរក្សាទុកកំណត់ត្រា ឯកសារ និងឯកសារចម្លងទាំងអស់ដែលទាក់ទងនឹងគ្រប់រូបភាពនៃប្រតិបត្តិការឱ្យបានយ៉ាងតិចរយៈពេល ៥ ឆ្នាំ នៅក្រោយពេលធ្វើប្រតិបត្តិការ ។ គ្រប់ទិន្នន័យអត្តសញ្ញាណ កំណត់ត្រា ឯកសារលិខិតទំនាក់ទំនងអាជីវកម្ម និងឯកសារចម្លង ដែលទទួលបានក្នុងនីតិវិធីយកចិត្តទុកដាក់ស្គាល់អតិថិជនត្រូវតែរក្សាទុកឱ្យបានយ៉ាងតិច ៥ ឆ្នាំ បន្ទាប់ពីបិទគណនី ឬបន្ទាប់ពីបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជន ។

១៩.២ ករណីដែលកំណត់ត្រាទុកជាកម្មវត្ថុនៃការស៊ើបអង្កេតជាបន្តបន្ទាប់ ឬនៃរបាយការណ៍ប្រតិបត្តិការសង្ស័យ កំណត់ត្រានោះត្រូវរក្សាទុកឱ្យបានលើសពីរយៈពេលដែលបានកំណត់រហូតដល់អាជ្ញាធរដែលពាក់ព័ន្ធនឹងការស៊ើបអង្កេតបញ្ជាក់ថា ឯកសារទាំងនោះលែងមានសារប្រយោជន៍ ។

ប្រការ ២០.- ដាននៃសវនកម្ម

២០.១ បុគ្គលរាយការណ៍ ត្រូវធានាថា រាល់ឯកសារ និងកំណត់ត្រាដែលបានរក្សាទុក បង្កើតជាដានសវនកម្មចំពោះប្រតិបត្តិការនីមួយៗ ដែលជួយភ្នាក់ងារត្រួតពិនិត្យ និងភ្នាក់ងារមានសមត្ថកិច្ចដើម្បីតាមដានមូលនិធិ ។

២០.២ កំណត់ត្រាដែលបានរក្សាទុកទាំងនោះ ត្រូវតែអាចជួយបុគ្គលរាយការណ៍ឱ្យបង្កើតប្រវត្តិនិងលក្ខណៈ និងបង្កើតប្រតិបត្តិការនីមួយៗឡើងវិញបាន ។ កំណត់ត្រាទាំងនោះ យ៉ាងហោចណាស់ត្រូវមាន ៖

- ប្រភពមូលនិធិ ដូចជាវិធីសាស្ត្រនៃការទទួល និង/ឬអ្នកផ្តើមប្រតិបត្តិការផ្ទេរប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច ..

- អត្តសញ្ញាណបុគ្គលដែលធ្វើប្រតិបត្តិការ ប្រសិនបើមិនមែនជាម្ចាស់គណនី
- ប្រភេទប្រតិបត្តិការ និង
- ការណែនាំ និងគោលដៅនៃការផ្ទេរមូលនិធិ ។

ប្រការ ២១.- ទម្រង់ឯកសារដែលរក្សាទុក

បុគ្គលរាយការណ៍ ត្រូវរក្សាទុកឯកសារពាក់ព័ន្ធ ជាច្បាប់ដើម ឬថតចម្លង ឬមីក្រូហ្វីល ឬក្នុងទម្រង់អេឡិកត្រូនិកដែលមានសុវត្ថិភាព និងអាចយកមកប្រើប្រាស់នៅពេលត្រូវការដោយត្រឹមត្រូវនិងទាន់ពេលវេលា ។

ប្រការ ២២.- ការតាមដានបន្ត

២២.១ បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាបន្ត ចំពោះទំនាក់ទំនងជាមួយអតិថិជនទាំងអស់ ដោយប្រើប្រាស់វិធីសាស្ត្រផ្អែកតាមហានិភ័យ ។ វិធីសាស្ត្រនេះ ត្រូវធានាថាសាវតារហានិភ័យរបស់អតិថិជនត្រូវបានធ្វើបច្ចុប្បន្នកម្ម ។

២២.២ បុគ្គលរាយការណ៍ ត្រូវយកចិត្តទុកដាក់ជាពិសេស និងបន្តអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនសម្រាប់គ្រប់ប្រតិបត្តិការធំៗ មិនប្រក្រតី ស្មុគស្មាញ ឬគំរូនៃប្រតិបត្តិការមិនប្រក្រតីដើម្បីកំណត់ថាតើប្រតិបត្តិការទាំងនេះមានឬពុំមានគោលបំណងស្របច្បាប់ច្បាស់លាស់ ។

ប្រការ ២៣.- ប្រព័ន្ធព័ត៌មានគ្រប់គ្រង

បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រប់គ្រាន់មួយ ដើម្បីអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនរបស់ខ្លួន សម្រាប់សម្គាល់អត្តសញ្ញាណ និងរកឱ្យឃើញនូវប្រតិបត្តិការទាំងឡាយណាដែលខ្លួនសង្ស័យ ឬមានមូលដ្ឋានសមស្របដើម្បីសង្ស័យលើប្រតិបត្តិការ ដែលជាប់ពាក់ព័ន្ធនិងផលដែលបានមកពីសកម្មភាពខុសច្បាប់ ឬអតិថិជនដែលជាប់ទាក់ទងនឹងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ។ ប្រព័ន្ធព័ត៌មានគ្រប់គ្រងត្រូវផ្តល់ឱ្យបុគ្គលរាយការណ៍នូវព័ត៌មានទៀងទាត់ពេលវេលា ដើម្បីអាចរកសកម្មភាពសង្ស័យ ។

ប្រការ ២៤.- ការយកចិត្តទុកដាក់ពិសេស

បុគ្គលរាយការណ៍ ត្រូវអនុវត្តការយកចិត្តទុកដាក់ស្គាល់អតិថិជនជាប្រចាំ ចំពោះទំនាក់ទំនងអាជីវកម្ម និងប្រតិបត្តិការជាមួយឯកត្តបុគ្គល អាជីវកម្ម ក្រុមហ៊ុន និងគ្រឹះស្ថានហិរញ្ញវត្ថុ មកពីបណ្តាប្រទេសដែលមិនបានអនុវត្តពេញលេញតាមវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលទទួលស្គាល់ជាអន្តរជាតិ ។ បុគ្គលរាយការណ៍ត្រូវសួរសំណួរបន្ថែមពីគោលបំណង ប្រវត្តិប្រតិបត្តិការ និងទំនាក់ទំនងអាជីវកម្មឱ្យបានលម្អិត ជាលាយលក្ខណ៍អក្សរ និងបញ្ជូនទៅដល់អាជ្ញាធរមានសមត្ថកិច្ច ។

ប្រការ ២៥.- របាយការណ៍ប្រតិបត្តិការសាច់ប្រាក់

២៥.១ បុគ្គលរាយការណ៍ ត្រូវរាយការណ៍មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នូវប្រតិបត្តិការសាច់ប្រាក់ដែលស្មើ ឬលើសពី សែសិបលានរៀល (៤០.០០០.០០០រ) ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត ។

២៥.២ របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ត្រូវផ្តល់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា កំឡុងពេល ១៤ ថ្ងៃ ក្រោយកាលបរិច្ឆេទនៃប្រតិបត្តិការ ហើយត្រូវបំពេញក្នុងទម្រង់ "របាយការណ៍ប្រតិបត្តិការសាច់ប្រាក់" ដែលបានអនុម័តដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ឬទម្រង់ដែលអនុម័តសម្រាប់ការរាយការណ៍តាមអេឡិចត្រូនិក ។ អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ត្រូវផ្តល់ឱ្យបុគ្គលរាយការណ៍នូវច្បាប់ចម្លងនៃទម្រង់របាយការណ៍ប្រតិបត្តិការសាច់ប្រាក់ ។

២៥.៣ ប្រតិបត្តិការសាច់ប្រាក់ ដែលអាចរាយការណ៍បាន រួមមាន ប្រតិបត្តិការសាច់ប្រាក់ច្រើនដងរបស់អតិថិជនម្នាក់ ឬគណនីមួយដែលមានចំនួនសរុបនៃប្រតិបត្តិការរួមគ្នាក្នុងមួយថ្ងៃ ឬចំនួនសាច់ប្រាក់ដកចេញពីការឈ្នះល្បែង ដែលស្មើ ឬលើសពីសែសិបលានរៀល (៤០.០០០.០០០រ) ឬសមមូលនឹងរូបិយប័ណ្ណផ្សេងទៀត។

ប្រការ ២៦.- របាយការណ៍ប្រតិបត្តិការសង្ស័យ

២៦.១ បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធរាយការណ៍ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យភ្លាមៗ មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅពេលមានការសង្ស័យ ឬមានមូលដ្ឋានសមស្របសង្ស័យថាប្រតិបត្តិការនោះជាប់ពាក់ព័ន្ធនឹងប្រាក់បានមកពីបទល្មើស ឬអតិថិជនដែលជាប់ពាក់ព័ន្ធនឹងការសម្អាតប្រាក់ ឬហិរញ្ញប្បទានភេរវកម្ម ។ បុគ្គលរាយការណ៍ត្រូវបង្កើតសេចក្តីណែនាំផ្ទៃក្នុងផ្ទាល់ខ្លួនអំពីរបាយការណ៍ប្រតិបត្តិការសង្ស័យ ដោយផ្សារភ្ជាប់ជាមួយច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម និងបញ្ញត្តិដែលបានចែងនៅក្នុងប្រកាសនេះ និងសូចនាករប្រតិបត្តិការសង្ស័យដែលមានចែងនៅក្នុងសេចក្តីណែនាំចេញផ្សាយដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាផងដែរ ។

២៦.២ បុគ្គលរាយការណ៍ ត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យ នៅពេលដែលអតិថិជនថ្មីឬអតិថិជនបច្ចុប្បន្នមិនបានបំពេញកាតព្វកិច្ចយកចិត្តទុកដាក់ស្គាល់អតិថិជនដោយគ្មានហេតុផលសមស្រប ដោយពុំគិតថាបុគ្គលរាយការណ៍ទទួលយក បដិសេធ បន្ត ឬបញ្ចប់ទំនាក់ទំនងអាជីវកម្មជាមួយអតិថិជននោះ ។

ប្រការ ២៧.- យន្តការរាយការណ៍

២៧.១ បុគ្គលរាយការណ៍ ត្រូវតែងតាំងមន្ត្រីថ្នាក់គ្រប់គ្រងជាន់ខ្ពស់មួយរូប ធ្វើជាមន្ត្រីប្រតិបត្តិទទួលខុសត្រូវក្នុងការបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា។ មន្ត្រីប្រតិបត្តិ

ដែលបានទទួលការតែងតាំង ត្រូវដើរតួនាទីជាអ្នកទំនាក់ទំនងតែម្នាក់គត់ជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។ បុគ្គលរាយការណ៍ ត្រូវធានាថា រាល់របាយការណ៍ប្រតិបត្តិការសង្ស័យដែលបានធ្វើឡើងដោយនិយោជិតត្រូវបានផ្តល់ឱ្យមន្ត្រីប្រតិបត្តិយ៉ាងសមស្រប ។

២៧.២ បុគ្គលរាយការណ៍ ត្រូវណែនាំនិយោជិតឱ្យរាយការណ៍ប្រតិបត្តិការសង្ស័យទៅមន្ត្រីប្រតិបត្តិ ទោះបីជាគេពុំដឹងច្បាស់ថាប្រតិបត្តិការនោះជាសកម្មភាពខុសច្បាប់ ឬពិតជាកើតឡើងក៏ដោយ ។

២៧.៣ នៅពេលទទួលបានរបាយការណ៍ប្រតិបត្តិការសង្ស័យ មន្ត្រីប្រតិបត្តិត្រូវវាយតម្លៃ និងកំណត់ភ្លាមៗ ពីមូលដ្ឋានសមហេតុផលក្នុងការសង្ស័យ និងត្រូវបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនេះជាបន្ទាន់មកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងរយៈពេល ២៤ ម៉ោង ប្រសិនបើមន្ត្រីប្រតិបត្តិគិតថាគ្មានមូលហេតុសមហេតុផលទេនោះ ត្រូវកត់ត្រាតែមតិរបស់ខ្លួនប៉ុណ្ណោះ ។

២៧.៤ របាយការណ៍ប្រតិបត្តិការសង្ស័យ ដែលបញ្ជូនមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដោយមន្ត្រីប្រតិបត្តិត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយប្រើប្រាស់តារាងបំពេញដែលផ្តល់ដោយអង្គភាពស៊ើប-ការណ៍ហិរញ្ញវត្ថុកម្ពុជា ហើយប្រគល់ដោយសុវត្ថិភាព ដោយផ្ទាល់ដៃ ឬតាមសំបុត្រដែលមានសុវត្ថិភាព និង តាមអេឡិចត្រូនិកជាដើម ។

២៧.៥ បុគ្គលរាយការណ៍ ត្រូវធានាថា នៅពេលរៀបចំ និងបញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យនោះត្រូវរក្សាការសម្ងាត់ និងអាចដឹងព័ត៌មាននេះបានត្រឹមតែបុគ្គលិកមានសិទ្ធិប៉ុណ្ណោះ ។

២៧.៦ បុគ្គលរាយការណ៍ ត្រូវផ្តល់សិទ្ធិឱ្យមន្ត្រីប្រតិបត្តិសហការជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្នុងការផ្តល់ព័ត៌មាន និងឯកសារចាំបាច់បន្ថែមទៅតាមសំណើសុំ និងឆ្លើយតបរាល់ការសាកសួរដែល ពាក់ព័ន្ធនឹងរបាយការណ៍ប្រតិបត្តិការសង្ស័យ ។

ប្រការ ២៨.- ការហាមឃាត់ការផ្តល់ព័ត៌មាន

២៨.១ បុគ្គលរាយការណ៍ ត្រូវធានាថា ប្រព័ន្ធរាយការណ៍ដែលបានបង្កើតសម្រាប់បញ្ជូនរបាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានដំណើរការជាសម្ងាត់ ។

២៨.២ បុគ្គលរាយការណ៍ ត្រូវធានាថា អតិថិជនដែលត្រូវបានរាយការណ៍នេះ មិនត្រូវបានផ្តល់ព័ត៌មាន ឬមិនបានដឹងថាមានប្រតិបត្តិការនេះទេ ។ បុគ្គលិកទាំងអស់ត្រូវយល់ដឹងអំពី មាត្រា ១៥ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលបានចែងអំពី ការហាមឃាត់បុគ្គលណាដែលបានដឹងអំពីប្រតិបត្តិការសង្ស័យ មិនត្រូវផ្តល់ព័ត៌មាន ឬរាយការណ៍ទៅបុគ្គលផ្សេង ក្រៅពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា លើកលែងតែមានការអនុញ្ញាតពីអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

ប្រការ ២៩.- បញ្ហាផ្សេងទៀត

២៩.១ បុគ្គលរាយការណ៍ត្រូវរក្សាទុកឯកសារពេញលេញស្តីពីរបាយការណ៍ប្រតិបត្តិការសង្ស័យ ដែលនិយោជិតបានផ្ញើទៅមន្រ្តីប្រតិបត្តិ និងបានផ្ញើបន្តមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

២៩.២ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការសមហេតុផល ដើម្បីធ្វើយ៉ាងណាឱ្យមន្រ្តីនិងនិយោជិតដែលពាក់ព័ន្ធនឹងការអនុវត្ត ឬសម្របសម្រួលប្រតិបត្តិការរបស់អតិថិជនយល់ដឹងពីនីតិវិធីរាយការណ៍ ។

ប្រការ ៣០.- ការរកឃើញ និង រាយការណ៍ពីហិរញ្ញប្បទានភេរវកម្ម

៣០.១ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការចាំបាច់ ដើម្បីអនុវត្តឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងច្បាប់និងបទប្បញ្ញត្តិស្តីពីហិរញ្ញប្បទានភេរវកម្ម ។

៣០.២ បុគ្គលរាយការណ៍ ត្រូវធានាថា ប្រព័ន្ធនិងយន្តការរាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានពង្រីកគ្របដណ្តប់លើការសង្ស័យពីហិរញ្ញប្បទានភេរវកម្ម ។

៣០.៣ បុគ្គលរាយការណ៍ ត្រូវរក្សាមូលដ្ឋានទិន្នន័យ ដែលមានឈ្មោះនិងព័ត៌មានលម្អិតរបស់ភេរវករដែលមានក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ ហើយត្រូវយកចិត្តទុកដាក់ដល់ការបញ្ចូលគ្នារវាងមូលដ្ឋានទិន្នន័យរបស់ខ្លួន និងបញ្ជីឈ្មោះបុគ្គលដែលបានសម្គាល់អត្តសញ្ញាណផ្សេងទៀត ។ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្ម និងមានទំនាក់ទំនងគ្នា ហើយផ្តល់លទ្ធភាពងាយស្រួលដល់និយោជិតក្នុងការប្រើប្រាស់សម្រាប់សម្គាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងការបង្កកគណនីឬមូលនិធិ។

៣០.៤ បុគ្គលរាយការណ៍ ត្រូវពិនិត្យឈ្មោះអតិថិជនថ្មី និងអតិថិជនមានស្រាប់ជាមួយនឹងឈ្មោះដែលមាននៅក្នុងមូលដ្ឋានទិន្នន័យ ។ ប្រសិនបើមានឈ្មោះដូចគ្នា បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជននោះ ។ ប្រសិនបើឈ្មោះអតិថិជន និងឈ្មោះនៅក្នុងមូលដ្ឋានទិន្នន័យជាឈ្មោះតែមួយ ហើយជាមនុស្សតែម្នាក់ បុគ្គលរាយការណ៍ត្រូវបង្កកមូលនិធិ ឬទ្រព្យសកម្មរបស់អតិថិជននោះ និងត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាជាបន្ទាន់ ។ នៅពេលមានការសង្ស័យថា ប្រតិបត្តិការមួយពាក់ព័ន្ធនឹងភេរវករ បុគ្គលរាយការណ៍ត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យនោះមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

ប្រការ ៣១.- ការគ្រប់គ្រងហានិភ័យ

៣១.១ ក្រុមប្រឹក្សាភិបាលរបស់បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របតាមតម្រូវការនៃច្បាប់និងបទប្បញ្ញត្តិ ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឱ្យ មានប្រសិទ្ធភាព ។ ៧/

ប្រការ ២៩.~ បញ្ហាផ្សេងទៀត

២៩.១ បុគ្គលរាយការណ៍ត្រូវរក្សាទុកឯកសារពេញលេញស្តីពីរបាយការណ៍ប្រតិបត្តិការសង្ស័យ ដែលនិយោជិតបានផ្ញើទៅមន្ត្រីប្រតិបត្តិ និងបានផ្ញើបន្តមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

២៩.២ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការសមហេតុផល ដើម្បីធ្វើយ៉ាងណាឱ្យមន្ត្រីនិងនិយោជិតដែលពាក់ព័ន្ធនឹងការអនុវត្ត ឬសម្របសម្រួលប្រតិបត្តិការរបស់អតិថិជនយល់ដឹងពីនីតិវិធីរាយការណ៍ ។

ប្រការ ៣០.~ ការរកឃើញ និង រាយការណ៍ពីហិរញ្ញប្បទានភេរវកម្ម

៣០.១ បុគ្គលរាយការណ៍ ត្រូវចាត់វិធានការចាំបាច់ ដើម្បីអនុវត្តឱ្យស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងច្បាប់និងបទប្បញ្ញត្តិស្តីពីហិរញ្ញប្បទានភេរវកម្ម ។

៣០.២ បុគ្គលរាយការណ៍ ត្រូវធានាថា ប្រព័ន្ធនិងយន្តការរាយការណ៍ប្រតិបត្តិការសង្ស័យត្រូវបានពង្រីកគ្របដណ្តប់លើការសង្ស័យពីហិរញ្ញប្បទានភេរវកម្ម ។

៣០.៣ បុគ្គលរាយការណ៍ ត្រូវរក្សាមូលដ្ឋានទិន្នន័យ ដែលមានឈ្មោះនិងព័ត៌មានលម្អិតរបស់ភេរវករដែលមានក្នុងបញ្ជីរបស់អង្គការសហប្រជាជាតិ ហើយត្រូវយកចិត្តទុកដាក់ដល់ការបញ្ចូលគ្នារវាងមូលដ្ឋានទិន្នន័យរបស់ខ្លួន និងបញ្ជីឈ្មោះបុគ្គលដែលបានសម្គាល់អត្តសញ្ញាណផ្សេងទៀត ។ ព័ត៌មាននៅក្នុងមូលដ្ឋានទិន្នន័យត្រូវធ្វើបច្ចុប្បន្នកម្ម និងមានទំនាក់ទំនងគ្នា ហើយផ្តល់លទ្ធភាពងាយស្រួលដល់និយោជិតក្នុងការប្រើប្រាស់សម្រាប់សម្គាល់អត្តសញ្ញាណប្រតិបត្តិការសង្ស័យ និងការបង្កកគណនីឬមូលនិធិ។

៣០.៤ បុគ្គលរាយការណ៍ ត្រូវពិនិត្យឈ្មោះអតិថិជនថ្មី និងអតិថិជនមានស្រាប់ជាមួយនឹងឈ្មោះដែលមាននៅក្នុងមូលដ្ឋានទិន្នន័យ ។ ប្រសិនបើមានឈ្មោះដូចគ្នា បុគ្គលរាយការណ៍ត្រូវចាត់វិធានការសមស្របដើម្បីផ្ទៀងផ្ទាត់ និងបញ្ជាក់ពីអត្តសញ្ញាណរបស់អតិថិជននោះ ។ ប្រសិនបើឈ្មោះអតិថិជន និងឈ្មោះនៅក្នុងមូលដ្ឋានទិន្នន័យជាឈ្មោះតែមួយ ហើយជាមនុស្សតែម្នាក់ បុគ្គលរាយការណ៍ត្រូវបង្កកមូលនិធិ ឬទ្រព្យសកម្មរបស់អតិថិជននោះ និងត្រូវជូនដំណឹងមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាជាបន្ទាន់ ។ នៅពេលមានការសង្ស័យថា ប្រតិបត្តិការមួយពាក់ព័ន្ធនឹងភេរវករ បុគ្គលរាយការណ៍ត្រូវរាយការណ៍ប្រតិបត្តិការសង្ស័យនោះមកអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ។

ប្រការ ៣១.~ ការគ្រប់គ្រងហានិភ័យ

៣១.១ ក្រុមប្រឹក្សាភិបាលរបស់បុគ្គលរាយការណ៍ ត្រូវបង្កើតប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងឱ្យមានប្រសិទ្ធភាពដើម្បីប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របតាមតម្រូវការនៃច្បាប់និងបទប្បញ្ញត្តិ ។ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវទទួលខុសត្រូវអនុវត្តការត្រួតពិនិត្យផ្ទៃក្នុងឱ្យ មានប្រសិទ្ធភាព ។

៣១.២ ក្រុមប្រឹក្សាភិបាលនិងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ត្រូវដឹង និងយល់ពីវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលស្របតាមច្បាប់ បទប្បញ្ញត្តិ បទដ្ឋានតាមវិស័យនីមួយៗ និងការអនុវត្តដ៏ប្រសើរ ក៏ដូចជាសារសំខាន់នៃការបង្កើនឱ្យមានវិធានការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដើម្បីទប់ស្កាត់ការបំភាន់របស់អ្នកសម្អាតប្រាក់ និងអ្នកផ្តល់ហិរញ្ញប្បទានភេរវកម្មមកលើបុគ្គលរាយការណ៍ ។ ក្រុមប្រឹក្សាភិបាលត្រូវត្រួតពិនិត្យឱ្យបានល្អិតល្អន់លើវិធានការទូទៅប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ដែលត្រូវអនុវត្តដោយបុគ្គលរាយការណ៍ ។

៣១.៣ ក្រុមប្រឹក្សាភិបាល និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ត្រូវដឹងពីហានិភ័យនៃការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មពាក់ព័ន្ធនឹងរាល់សេវាកម្ម និងផលិតផលអាជីវកម្មរបស់ខ្លួន ។

